ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ</u>

លេខ: ០០៣/០៧-០៩-២០០៩/អវតក/កសចស(អបជ៣៥)

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2019, 14:38
CMS/CFO: Sann Rada

**<u>សាធារណៈ</u>**

**ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩**

**ម៉ោង ១១:២៤ នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ)

ចៅក្រម អូលីវីយេ បូវ៉ាល្លេត
*(Judge Olivier BEAUVALLET)*

ចៅក្រម ហួត វុទ្ធី

ចៅក្រម កាង ជីនបាក់
*(Judge Kang Jin BAIK)*

ចៅក្រម ន័យ ថុល

**ក្រឡាបញ្ជី៖**

លោកស្រី រស់ បូផាណា

កញ្ញា យូរី គីម *(Ms. Hyuree Kim)*

កញ្ញា មេឡានី ដេអេស
*(Ms. Melanie DESHAIES)*

លោក គ្រីស្តូហ្វឺ យូ *(Mr.Kristopher YUE )*

លោក ឡេអូ ចូលីវេត *(Mr. Leo JOLIVET)*

លោក ស៊ិន សុវណ្ណរ័ត្ន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោកស្រី ប្រេនដា ហូលិស
*(Mrs. Brenda HOLLIS)*

លោក ស្រ៊ា រតនៈ

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ ដេវីលដ៍ ដេស្មាឯល
*(Mr.Vincent de Wilde d’Estmael )*

លោកស្រី ហេឡេន វើសនុប
*(Ms. Helen Worsnop)*

**ជនត្រូវចោទ៖**

លោក មាស មុត (អវត្តមាន)

**មេធាវីការពារជនត្រូវចោទ៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr. Michael G KARNAVAS)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ) | ខ្មែរ |
| ចៅក្រម អូលីវីយេ បូវ៉ាល្លេត | បារាំង |
| ចៅក្រម កាង ជីនបាក់ | អង់គ្លេស |
| លោកស្រី ប្រេដាន ហូលិស | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ម៉ៃខល កាណាវ៉ាស | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[១១:២៤:៤០]

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះ!

សូមអញ្ជើញលោកចៅក្រមលើកជាសំណួរ។

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពភាគីទាំងអស់ ហើយនិងអ្នកដែលមានវត្តមាននៅទីនេះ។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់ភាគី។ សំណួរខ្ញុំទី១ ទាក់ទងទៅនឹង -- សួរទៅសហព្រះរាជអាជ្ញាជាតិ។

លោកសហព្រះរាជអាជ្ញាជាតិ អង្គាល់ដែលបង្ហាញអំពីបណ្តឹងឧទ្ធរណ៍នោះ គឺមានទទ្បីករណ៍មួយចំនួនទាក់ទងទៅនឹងការចេញដីកាដំណោះស្រាយទាំងពីរដែលផ្ទុយនឹងគ្នា។ ស្ថានភាពនេះវាមិនដែលមានទេពីមុនកន្លងមកនោះ វិធាន៦៧ នោះគឺថា យើងអាចមានចេញជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ តើការចេញដីកាពីរនេះ ក្នុងពេលតែមួយនោះ ធៀបទៅនឹងតម្លៃនៃដីកាពីរខុសគ្នានោះ តើលោកអាចពន្យល់យ៉ាងម៉េចដែរ?

**លោកស្រី ប្រេនដា ហូលិស៖**

សូមអរគុណលោកចៅក្រមចំពោះសំណួរនេះ។ អរុណសួស្តីលោកចៅក្រមទាំងអស់ មេធាវីការពារក្តី។ ជំហររបស់យើងខ្ញុំ ងាយស្រួលបំផុតដែលថាដីកាដំណោះស្រាយនីមួយៗត្រូវបានចេញដោយមានសុពលភាព។ ខ្ញុំមិននិយាយថាវាត្រឹមត្រូវគ្រប់គ្រាន់ទាំងអស់នោះទេ ក៏ប៉ុន្តែថាដីកាលើកលែងចោទប្រកាន់ ខ្ញុំលើកឡើងថាវាមានសំអាងហេតុមិនគ្រប់គ្រាន់។ យើងខ្ញុំសុំលើកឡើងថា បញ្ហាចម្រូងចម្រាសនៃដីកាដំណោះស្រាយនេះ វាអាចនឹងចេញអ៊ីចឹងហើយ ដោយសារតែសហចៅក្រមស៊ើបអង្កេតទាំងពីរនេះមានឋានៈស្មើគ្នា ប៉ុន្តែគាត់អាចយកបញ្ហាទាំងអស់នេះយកមកពិចារណានៅក្នុងដីកាដំណោះស្រាយដែលចេញផ្ទុយគ្នា។

យើងខ្ញុំថា នេះវាជាដំណោះស្រាយមួយល្អហើយ។ ជំហររបស់យើងខ្ញុំ គឺយកភាសាដែលមាននៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក, ច្បាប់ អ.វ.ត.ក, វិធានផ្ទៃក្នុង ហើយនិងការពិភាក្សារួមគ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរដែលលើកឡើងពីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះមកសំអាងផងដែរ។

ហើយយើង ក៏យើងមើលទៅលើគុណសម្បត្តិនៃដីកាដំណោះស្រាយទាំងពីរដែលត្រូវឲ្យមានការសម្រប សម្រួលនិងដោះស្រាយ។ កិច្ចព្រមព្រៀង អ.វ.ត.ក គឺថាយើងតែងតែយកមកពិចារណាចាំបាច់បំផុត។ សហចៅក្រមស៊ើបអង្កេតគាត់មានជំហរដូចគ្នា ដោយយោងទៅលើមាត្រា៦(៣) ពាក់ព័ន្ធទៅនឹងមុខងារ របស់សហចៅក្រមស៊ើបអង្កេតទាំងពីរ ហើយយើងក៏បានបកស្រាយទៅលើវិធាន១(២) ផងដែរ។ យោងទៅលើពាក្យថា "សហចៅក្រមស៊ើបអង្កេតទាំងពីរដែលត្រូវបំពេញកិច្ចរួមគ្នា ឬអាចបំពេញកិច្ច ដាច់ដោយឡែកពីគ្នា"។ នេះគឺជាទស្សនវិស័យរបស់យើង គឺថា ដឹងថាសហចៅក្រមស៊ើបអង្កេតអាច មានការមិនចុះសម្រុងគ្នា។ ទើបអ៊ីចឹងហើយបានទើបមានរឿងនេះដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

[១១:២៨:៣៥]

មាត្រា៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលអាចផ្តល់នូវយន្តការមួយសម្រាប់ដោះស្រាយបញ្ហា ហ្នឹង។ គឺការមិនចុះសម្រុងគ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ។ វាមានជម្រើសមួយនៅក្នុងមាត្រា នេះ ប៉ុន្តែការប្រើប្រាស់ជម្រើសនៅក្នុងមាត្រានេះ វាមិនមែនគេហៅថាដាច់ខាតនោះទេ។ ភាសានេះគឺ ភាសានៅក្នុងមាត្រានេះឯង។ វាមានអនុកថាខណ្ឌនិយាយពាក្យថា "ត្រូវតែ" ពាក្យនេះគឺថាជាពាក្យដាច់ ខាតតែម្តង ដែលប្រើពាក្យថា "ត្រូវតែជាដាច់ខាត"។ អនុកថាខណ្ឌ៤ ក៏មានពាក្យ "ត្រូវតែ" ដែរ ប៉ុន្តែ មិនបានយោងថាត្រូវឲ្យយកមកប្រើនៅក្នុងយន្តការដោះស្រាយសម្រាប់លទ្ធផលចម្បងៗនេះទេ។ អនុ កថាខណ្ឌជាបន្តបន្ទាប់និយាយថាសហចៅក្រមស៊ើបអង្កេត ត្រូវសហការគ្នាទាក់ទងទៅនឹងការយល់ ឃើញ ពាក់ព័ន្ធទៅនឹងការបំពេញកិច្ចស៊ើបសួរណាមួយ ប៉ុន្តែមាត្រានេះបន្តទៅនិយាយថា មាត្រានេះក៏ បន្តនិយាយថា "អាចនឹងមិនមានការយល់ស្របគ្នាហើយ"។ អ៊ីចឹងឯងត្រូវតែអនុវត្តមាត្រានេះឲ្យបាន ត្រឹមត្រូវ។ ភាសាដែលយើងខ្ញុំយោងនោះ នៅក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតមិនអាចយល់ ស្របគ្នាបាន ថាតើត្រូវបន្តកិច្ចស៊ើបសួរឬក៏អត់នោះ កិច្ចស៊ើបសួរត្រូវតែបន្តលើកលែងតែចៅក្រមទាំង ពីរ ឬក៏ចៅក្រមណាម្នាក់ស្នើសុំឲ្យអង្គបុរេជំនុំជម្រះដោះស្រាយការមិនចុះសម្រុងគ្នានេះ។ សូមមើល ពាក្យនៅក្នុងមាត្រា និយាយថា "ចៅក្រមស៊ើបអង្កេតម្នាក់ ឬទាំងពីរអាចស្នើសុំឲ្យអង្គបុរេជំនុំជម្រះដោះ ស្រាយ"។ ប៉ុន្តែសុំបញ្ជាក់ថា ការស៊ើបអង្កេតត្រូវតែបន្តបើមិនមានការស្នើសុំពីចៅក្រមណាម្នាក់ ឬទាំង ពីរទេ។ សុំបញ្ជាក់ម្តងទៀត កិច្ចស៊ើបសួរត្រូវតែបន្តបើមិនមានសំណើសុំណាមួយពីចៅក្រមម្នាក់ ឬទាំង ពីរដាក់ជូនអង្គបុរេជំនុំជម្រះ។

[១១:៣០:៥៤]

មាត្រា៧.១ ហ្នឹងក៏បានបន្តនិយាយអំពីយន្តការមិនចុះសម្រុងគ្នា គឺអាចអនុញ្ញាតឲ្យធ្វើបាន ប៉ុន្តែមិនមែនមានន័យថាដាច់ខាតនោះទេ ប៉ុន្តែបើសហចៅក្រមស៊ើបអង្កេតស្នើសុំមកអង្គបុរេជំនុំជម្រះនៅក្នុងអនុកថាខណ្ឌ៥ ដែលប្រើពាក្យថា "ត្រូវតែ"។ ដូច្នេះយើងខ្ញុំយល់ឃើញថាវាច្បាស់ហើយ ថាការប្រើយន្តការដើម្បីដោះស្រាយការមិនចុះសម្រុងគ្នា គឺអនុញ្ញាតឲ្យធ្វើទៅបាន ប៉ុន្តែមិនដាច់ខាតទេ។ ច្បាប់ អ.វ.ត.ក ក៏ចែងដូចគ្នាដែរ។ មាត្រា២៣(ថ្មី) ចែងអំពីការអនុញ្ញាតឲ្យប្រើប្រាស់យន្តការដោះស្រាយវិវាទនេះ បើមានការមិនចុះសម្រុងគ្នាក្នុងចំណោមសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងខាងក្រោមនេះត្រូវយកមកអនុវត្ត ការស៊ើបអង្កេតត្រូវតែបន្តទៅមុខ លើកលែងតែសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬចៅក្រមម្នាក់ស្នើសុំឲ្យអង្គបុរេជំនុំជម្រះដោះស្រាយការមិនចុះសម្រុងគ្នានេះ។

អ៊ីចឹង ខ្ញុំសុំសង្កត់ធ្ងន់ម្តងទៀត ពាក្យថា "ត្រូវតែ" គឺដាច់ខាតហើយ។ គឺការស៊ើបអង្កេតត្រូវតែបន្តដោយមានពាក្យថា "លើកលែងតែ" មានការស្នើសុំឲ្យប្រើយន្តការដោះស្រាយការមិនចុះសម្រុងគ្នានេះ។ អ៊ីចឹងយើងមានការកំណត់អាណត្តិដោយប្រើពាក្យថា "ត្រូវតែ"ជាដាច់ខាតហើយ។

[១១:៣២:២៤]

វិធានផ្ទៃក្នុង២២ និយាយអំពីការអនុវត្ត -- ៧២ គឺអនុវត្តពាក្យថា "អាច" នៅក្នុងអនុកថាខណ្ឌ២ នៃមាត្រា៧២ នេះអាចយកការមិនចុះសម្រុងគ្នាដាក់ចំពោះមុខអង្គបុរេជំនុំជម្រះបាន។ ហើយនៅក្នុងអនុកថាខណ្ឌ៤ ពាក់ព័ន្ធទៅនឹងស្ថានភាពដែលសហចៅក្រមស៊ើបអង្កេតសម្រេចថា សម្រេចផ្សេងគ្នានៅពេលនោះប្រើពាក្យថា "ត្រូវតែ"។ គឺមានពាក្យ "ត្រូវតែ"។ ក៏ដូចជាវិធាន ៧៧(១៣)(ខ), វិធាន ៦៧ គឺនិយាយដែរថា សហចៅក្រមស៊ើបអង្កេតត្រូវតែចេញការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ត្រូវតែបកស្រាយឲ្យស្របផ្គួបគ្នាជាមួយនឹងវិធានផ្ទៃក្នុង ១(២) ។ ដូច្នេះ ចំណុចនេះនិយាយអំពីថា ចៅក្រមទាំងពីរអាចបំពេញកិច្ចរួមគ្នា ឬក៏បំពេញកិច្ចដាច់ដោយឡែកបាន នៅពេលដែល -- ហើយអាចចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នាបាន។ ហើយដីកាដំណោះស្រាយដែលផ្ទុយគ្នានេះ យើងខ្ញុំ នៅក្នុងសំណើសុំរបស់ អោ អាន ឲ្យបង្ហាញឯកសារទាក់ទងទៅនឹងការមិនចុះសម្រុងគ្នានេះ គឺឯកសារ D262/2 នៅក្នុងត្រង់កថាខណ្ឌ១៤ ចុះថ្ងៃទី១៨ កញ្ញា សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិអាចសម្រេចចេញដីកាដំណោះស្រាយផ្ទុយគ្នាបានដោយយោងទៅលើច្បាប់ជាធរមាន។ សុំដកស្រង់៖ "ដោយមានសំអាងហេតុដូចគ្នា ដោយមានការលើកឡើង គឺ នេះគឺជាសេចក្តីសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតទាំងពីរនៅក្នុងសេចក្តីសម្រេចលើសំណើរបស់ អោ អាន សុំឲ្យបញ្ជាក់ការមិនចុះ

សម្រុងគ្នា គឺ D3/5/1 នៅក្នុងសេចក្ដីសម្រេចនេះ គឺមានការវិភាគថា កិច្ចព្រមព្រៀង អ.វ.ត.ក គឺពាក់ព័ន្ធទៅនឹងសហព្រះរាជអាជ្ញាទាំងពីរ គឺនៅក្នុងកថាខណ្ឌ ៦.៤។ ហើយនៅក្នុងច្បាប់បង្កើត អ.វ.ត.ក មាត្រា ២០(ថ្មី) និងមាត្រា ២៣(ថ្មី) គឺភាសានេះដូចគ្នាទេ ប្រើភាសាតែមួយទេ។

[១១:៣៤:៥៦]

វិធាន៧១ វិញ ហើយបើមើលទៅលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះមួយចំនួន ខ្ញុំសុំបញ្ជាក់ថា វាជាសម្រេចបង្កើតថ្មីមួយសម្រេចដោយឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ ជម្រើសក្នុងការចេញដីកាដំណោះស្រាយផ្ទុយគ្នាពីរនេះ វាមានន័យមិនជាអ្វីទេ។ គឺថាបើសិនណាសហចៅក្រមស៊ើបអង្កេតចេញបែបនេះ គឺមានយន្តការអនុញ្ញាតឱ្យចេញ -- គឺមាននៅក្នុងកិច្ចព្រមព្រៀងមាត្រា ៥.៤ និង ៧ ក៏ដូចជាវិធាន៧២ ដែលនិយាយអំពីយន្តការដាច់ខាតសម្រាប់ដោះស្រាយការមិនចុះសម្រុងគ្នានេះ។ បន្ថែមលើនេះទៅទៀតវាមានការអនុវត្តឆន្ទានុសិទ្ធិ សិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតនីមួយៗដាច់ដោយឡែកពីគ្នា។ យើង ខ្ញុំសុំនិយាយថាមិនឱ្យមានការសម្របសម្រួលបញ្ហានេះទេ គឺត្រូវតែរកសំឡេងភាគច្រើនលើសលុបឱ្យបាន។ បើមិនបានទេ សំណុំរឿងនេះត្រូវតែបញ្ជូនទៅជំនុំជម្រះ។ រឿង អោ អាន ក៏ដូចគ្នាអ៊ីចឹងដែរ បើរកមិនបានសំឡេងភាគច្រើនលើសលុបទេ ត្រូវតែបញ្ជូនគាត់ទៅជំនុំជម្រះដូចគ្នា។ យន្តការទាំងអស់នេះវាជួយសម្រួលទៅដល់អង្គជំនុំជម្រះផងដែរ។ គុណវិបត្តិនោះ គឺការចេញដីកាដំណោះស្រាយមួយជាការចាំបាច់បំផុត ប៉ុន្តែដោយសារតែយើងមានដីកាដំណោះស្រាយ និងជំហរពីរផ្ទុយគ្នាហ្នឹង ម្នាក់សម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ចៅក្រមម្នាក់សម្រេចលើកលែងចោទប្រកាន់។ អ៊ីចឹងតើយើងដោះស្រាយចំណុចដែលមិនអាចផ្សះផ្សាគ្នាបាននេះដោយរបៀបណា ដែលថាសហចៅក្រមស៊ើបអង្កេតមួយត្រូវបំពេញកិច្ចដោយឯករាជ្យ ហើយក៏ចេញដីកាមួយចុះហត្ថលេខាតែម្នាក់ឯង ហើយដីកាមួយទៀតចេញផ្ទុយទៅនឹងចៅក្រមមួយទៀត ហើយចៅក្រមម្នាក់ចេញ លើកលែងអ៊ីចឹង តើគាត់ធ្វើម៉េចនឹងបានទៅចុះហត្ថលេខារួមគ្នាជាមួយដីកាមួយទៀតទៅបាន? អ៊ីចឹងយើងមិនរំពឹងថា -- ឬប៉ុន្តែដោយសារចៅក្រមហ្នឹងគាត់មានអំណាចឯករាជ្យរៀងខ្លួន។ ចំណុចនេះគឺបញ្ជាក់អំពីការសម្រេចចិត្តរបស់គាត់ ប៉ុន្តែបើគាត់សម្រេចបែបហ្នឹង តើការសម្រេចបែបនេះគឺត្រូវបង្ហាញមូលហេតុដោយរបៀបណា។ យើងខ្ញុំរំពឹងថាវានឹងមានការចេញដីកាដំណោះស្រាយតែមួយលើកឡើងនូវអង្គហេតុរួមគ្នា ក្នុងស្ថានភាពតែមួយ ប៉ុន្តែនៅទីនេះ គឺថាវាមានកិច្ចនីតិវិធីដែលតម្រូវឱ្យមានការសម្របសម្រួលឱ្យចេញដីកាដំណោះស្រាយតែមួយ។ អ៊ីចឹងការចេញដីកាដំណោះស្រាយពីរបែបនេះ គឺតម្រូវឱ្យមានការ

សម្របសម្រួលពីរសំណាក់អង្គបុរេជំនុំជម្រះ។ មួយ ត្រូវលើកលែងចោទប្រកាន់, មួយ បញ្ជូនទៅជំនុំជម្រះ។ អ៊ីចឹងទៅសម្របសម្រួលវា។ ហើយត្រូវមើលសំអាងហេតុរបស់ដីការនីមួយៗថាតើវាមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យអង្គបុរេជំនុំជម្រះឈានដល់ការធ្វើសេចក្ដីសម្រេច។ ហើយក៏ដើម្បីឱ្យភាគីហ្នឹងទទួលបានឯកសារពាក់ព័ន្ធទៅនឹងការមិនចុះសម្រុងគ្នានេះ ឱ្យបានពេញលេញដែរ។ ហើយក៏វាសម្រាប់ឱ្យចៅក្រមអង្គបុរេជំនុំជម្រះមានសំអាងហេតុគ្រប់គ្រាន់សម្រាប់ដោះស្រាយវិវាទនេះផងដែរ។ គឺសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកានីមួយៗនេះដើម្បីដោះស្រាយដោយយើងប្រើបទដ្ឋានសម្រាប់តុលាការជាន់ខ្ពស់ ថាតើជំហានបន្ទាប់ត្រូវធ្វើដូចម្ដេច ក្រោយពីទទួលបានបណ្ដឹងឧទ្ធរណ៍ហើយ។ ការអនុវត្តជម្រើស ដោះស្រាយដីកាដំណោះស្រាយទាំងពីរ ទោះបីផ្ទុយគ្នាក៏ដោយ ក៏វាចូលរួមចំណែកបង្ហាញអំពីដំណើរការតុលាការប្រកបដោយតម្លាភាពនៅ អ.វ.ត.ក នេះជាសាធារណៈតែម្ដង។

[១១:៣៩:៤២]

ម្យ៉ាងទៀត បើសិនជាអង្គបុរេជំនុំជម្រះត្រូវបង្ខំឱ្យសហចៅក្រមស៊ើបអង្កេតឱ្យដោះ ឱ្យយកដំណោះស្រាយយន្តការនេះ ហើយបើមិនព្រមកែប្រែ មិនរកដំណោះស្រាយភាពខុសគ្នានេះទេ អ៊ីចឹងភាគីសុំឱ្យធ្វើម៉េចឱ្យទុកឱ្យសម្របសម្រួលគ្នានេះចាត់ទុកថាជាការសម្ងាត់។ ហើយចុងក្រោយនេះ គឺថាបើរកមិនឃើញទេ មានតែសំឡេងភាគច្រើនលើសលុបនេះហើយដែលជាដំណោះស្រាយ។ មិនមានការហាមឃាត់មិនឱ្យចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាទេ។ មិនមានការហាមឃាត់អ៊ីចឹងទេ។

ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នានេះ ពីសំណាក់ចៅក្រមដែលមានឋានៈប៉ុនគ្នា ឯករាជ្យហើយមានទទួលអាណត្តិឱ្យបំពេញកិច្ចរៀងខ្លួន។ អ៊ីចឹងយើងត្រូវពិនិត្យមើល ថាតើវាមានគុណសម្បត្តិគុណវិបត្តិបែបណា។ ចៅក្រមស៊ើបអង្កេតដែលឯករាជ្យដូចគ្នា ហើយមានជំហរពីរខុសគ្នា គឺអ៊ីចឹងឯងហើយបានជាគាត់ចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាបែបនេះនោះ។

[១១:៤០:៥៦]

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

បាទ សូមអរគុណលោកស្រីព្រះរាជអាជ្ញា។ សំណួរទី២របស់ខ្ញុំគឺ យោងទៅនឹងការពិភាក្សាគ្នាកន្លងមកនេះ បើអង្គបុរេជំនុំជម្រះមិនច្រឡំទេ លោកស្រីបាននិយាយកាលពីថ្ងៃពុធនេះថា លោកស្រីយល់ឃើញថា មិនជាប់កាតព្វកិច្ចពីការរកឃើញនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ តើលោកស្រីយល់យ៉ាងម៉េចដែរ ត្រង់ចំណុចនេះ?

**លោកស្រី ប្រេនដា បូលិស៖**

សូមអរគុណលោកចៅក្រម។ ការលើកឡើងជាលម្អិតទៅលើចំណុចនេះ ខ្ញុំសូមលើកឡើងថា វាសំខាន់ណាស់ ថាត្រូវពិចារណាទៅលើបរិបទដែលយើងខ្ញុំបានលើកឡើង។ យើងខ្ញុំមិននិយាយថា យើងជាប់កាតព្វកិច្ចទាំងអស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះទេ។ យើងត្រូវតែមើលបរិបទនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្ញុំ។ ដោយសារយើងខ្ញុំលើកឡើងថា ដីកាលើកលែងការចោទប្រកាន់នេះ ខុសទាំងស្រុង ដោយមិនបានសំអាងទៅអង្គហេតុទាំងអស់ដែលមាននៅក្នុងសំណុំរឿង ឬក៏យោងទៅលើការវាយតម្លៃមួយដែលវាមិនសុក្រឹត។ សហការីរបស់ខ្ញុំកាលពីថ្ងៃពុធ លើកឡើងមកហើយ អំពីសមាជិកភាពរបស់ មាស មុត នៅក្នុងគណៈមជ្ឈិម ហើយគាត់បានពន្យល់ជូនអង្គជំនុំជម្រះថា ហេតុអីបានយើងលើកឡើងថា ដីកាលើកលែងចោទប្រកាន់មានកំហុសក្នុងការយោងទៅលើសក្ខីកម្មរបស់សាក្សីផ្ទាល់ម្នាក់ គឺខៀវ សំផន នេះឯង។ ដោយសារ ខៀវ សំផន ខ្លួនគាត់ ជាសមាជិកគណៈមជ្ឈិម។ ហើយដីកានោះទៀត ក៏ទៅជាយោងទៅលើចម្លើយរបស់ ឌុច ដែលមិនសូវឱ្យជឿជាក់បានពេញលេញទេ។ ព្រោះគាត់មិនមែនជាសមាជិកគណៈមជ្ឈិមទេ។

[១១:៤២:៤២]

អ៊ីចឹង ដីកាលើកលែងចោទប្រកាន់សន្និដ្ឋានថា មាស មុត មិនដែលធ្លាប់ធ្វើជាសមាជិកមជ្ឈិមទេ គ្រាន់តែជាជំនួយការឱ្យគណៈមជ្ឈិមតែប៉ុណ្ណោះ។ អ៊ីចឹង ខ្ញុំសូមលើកឡើងថា យើងនឹងពិនិត្យទៅលើ-- អ៊ីចឹងហើយយើងខ្ញុំមើលកំហុសទាំងអស់ហ្នឹង ដែលលើកឡើងនៅក្នុងដីកាលើកលែងចោទប្រកាន់ហ្នឹង វាមិនត្រឹមត្រូវទេ។ ហើយយើងខ្ញុំបញ្ជាក់ចំណុចនេះ ក្នុងដីការបស់យើងខ្ញុំ។ ដូច ខៀវ សំផន លើកឡើង អ៊ីចឹង មាស មុត ថាជាសមាជិកពេញសិទ្ធិ ឬក៏សមាជិកត្រៀមនៃគណៈមជ្ឈិម។ ក្នុងន័យនេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចដកចេញនូវកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតជាតិ ដែលត្រូវពិនិត្យមើលភស្តុតាងទាំងអស់ក្នុងសំណុំរឿង។ វាយតម្លៃប្រកបទៅដោយហេតុផល មុននឹងឈានចេញទៅធ្វើសេចក្ដីសម្រេចទៅលើអង្គហេតុណាមួយនោះ។ ហើយត្រូវបង្ហាញអង្គហេតុនោះ ឱ្យបានពេញលេញទៀតផង។

ហើយយើងខ្ញុំក៏សូមធ្វើការកត់សម្គាល់ផងដែរ ថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅកថាខណ្ឌ ១៥០ គឺកថាខណ្ឌ -- មាស មុត ជាសមាជិកត្រៀម ឬក៏សមាជិកបម្រុងរបស់គណៈមជ្ឈិម នៅចុងឆ្នាំ-- ចាប់ពីចុងឆ្នាំ៧៧ ហើយគាត់ក៏ជាសមាជិកនៃគណៈកម្មាធិការយោធាផងដែរ។

[១១:៤៤:00]

ដូច្នេះ យើងខ្ញុំសូមសង្កត់ធ្ងន់ថា យើងយល់ស្របជាមួយដីកាយល់ព្រមជំនុំជម្រះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មាស មុត បានក្លាយទៅជាសមាជិកគណៈមជ្ឈិម។ នៅកថាខណ្ឌ៣៩៥ នៃដីកាលើកលែងចោទប្រកាន់ ដែលនិយាយថា មាស មុត មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ផ្ទុយពីជំហររបស់យើងខ្ញុំនោះ។ សូមអរគុណ។

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

បាទ សូមអរគុណលោកស្រីព្រះរាជអាជ្ញា។ ខ្ញុំសូមបញ្ចប់សំណួរជាមួយលោកស្រីហើយ ហើយឥឡូវនេះ ខ្ញុំមានសំណួរមួយសម្រាប់ព្រះរាជអាជ្ញាជាតិ។

លោកព្រះរាជអាជ្ញា លោកបានឮពេលដែលយើងពិភាក្សាគ្នានេះ អំពីការអះអាងមួយចំនួន។ តើលោកឆ្លើយយ៉ាងម៉េចដែរ ឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិនេះ គាត់និយាយថា បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាជាតិហ្នឹង មិនឆ្លើយតបនឹងលក្ខណៈតម្រូវដើម្បីយកទៅពិនិត្យឡើងវិញ ហើយនិងមិនមានអំណះអំណាងអីច្បាស់លាស់ទេ ហើយមិនបានបញ្ជាក់អំពីអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុនេះទេ។ អ៊ីចឹង ហើយដែលថាដីកាលើកលែងចោទប្រកាន់ហ្នឹង គឺបង្កឱ្យមានយុត្តិនិសេធអីជាដើមនេះ។ លោកមានមតិយោបល់យ៉ាងម៉េចដែរ?

[១១:៤៥:២៨]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកចៅក្រម ដែលបានដាក់សំណួរ។

ខ្ញុំសូមជម្រាបជូនដែរថា គោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌដោយចង្អៀត ជាគោលការណ៍ទូទៅមួយដែលត្រូវអនុវត្ត។ ការបកស្រាយដោយទូលាយទៅលើការកំណត់តួនាទី និងការទទួលខុសត្រូវរបស់ មាស មុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅចំពោះមុខយុត្តាធិការរបស់ អ.វ.ត.ក គឺជាការបកស្រាយដែលមិនស្របទៅតាមគោលការណ៍ដែលបានលើកឡើងពីខាងដើម។ គួរកត់សម្គាល់ផងដែរថា តួនាទី និងការទទួលខុសត្រូវរបស់ មាស មុត គឺសហព្រះរាជអាជ្ញាជាតិបានបញ្ជាក់នៅក្នុងបណ្ដឹងឧទ្ធរណ៍រួចហើយ។ សហព្រះរាជអាជ្ញាជាតិយល់ឃើញថា ទោះបីជា មាស មុត មានតួនាទីមួយចំនួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ មាស មុត មិនមានស្វ័យភាព និងសិទ្ធិអំណាចជាក់ស្ដែងនោះទេ។ រាល់ការចូលរួមសកម្មភាពការងារផ្សេងៗរបស់

មាស មុត គឺធ្វើឡើងតាមបញ្ជា និងការណែនាំរបស់អង្គការថ្នាក់លើ។ ព្រោះផែនការ និងទិសដៅផ្សេង ៗ របស់ មាស មុត គឺមាស មុត ត្រូវធ្វើតាមបញ្ជាថ្នាក់លើដោយគ្មានការដេញដោលឡើយ។

[១១:៤៦:៥៩]

មួយវិញទៀត សហព្រះរាជអាជ្ញាជាតិបានលើកឡើងអំពីទឡ្ហីករណ៍នានា នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ពីការបកស្រាយយុត្តាធិការបុគ្គលដែលមិនត្រឹមត្រូវរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលនេះជាកំហុសអង្គច្បាប់។ នៅពេលដែល មាស មុត មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ផងនោះ មិនគប្បីមានដីកាដំណោះស្រាយបញ្ជូនទៅជំនុំជម្រះតាំងពីដំបូងមក។ កំហុសអង្គច្បាប់នៃការកំណត់យុត្តាធិការបុគ្គលនេះ គឺគ្រប់គ្រាន់ និងពេញលេញ ដើម្បីឱ្យអង្គបុរេជំនុំជម្រះមានមូលដ្ឋានសម្រេច ដោយសំអាងហេតុក្នុងបណ្តឹងឧទ្ធរណ៍នេះបានហើយ បាទ។ សូមអរគុណ។

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

បាទ សូមអរគុណលោកព្រះរាជអាជ្ញា។

សំណួរខ្ញុំ សួរទៅខាងមេធាវីការពារក្តី។ បាទ សំណួរទី១ខ្ញុំ ទាក់ទងទៅនឹងភាពពន្យល់ឱ្យបាននៃបណ្តឹងឧទ្ធរណ៍របស់លោកមេធាវី មានពីរចំណុច។ ក្នុងមូលដ្ឋានទី១របស់លោក គឺលោកនិយាយថា សហចៅក្រមស៊ើបអង្កេតហ្នឹងបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបកស្រាយវិធាន៧៧(១៣) ដែលវិធីនេះបង្ហាញថាការចេញដំណោះស្រាយទាំងពីរហ្នឹង ទាំងពីរ ឬមានតែមួយហ្នឹង គឺមានអនុភាពអនុវត្ត។ លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចតម្កល់ដីកាដំណោះស្រាយណាមួយ ឱ្យសំឡេងភាគច្រើនលើសលុប។ នៅក្នុងមូលដ្ឋាន (ក) លោកទទួលស្គាល់ថា នៅកថាខណ្ឌ៣២ គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិហ្នឹង មិនមានសិទ្ធិអីបញ្ចេញទស្សនៈអ៊ីចឹងទេ ទៅលើបណ្តឹងឧទ្ធរណ៍នោះ។ ហើយបើតាមការស៊ើបអង្កេតហ្នឹង គឺថាចំណុចទី១ តើលោកគិតយ៉ាងណាដែរអំពីការទទួលយកបាននៃមូលដ្ឋានទី១របស់លោកនោះ អនុលោមតាមវិធាន៧៤(៣) ចំណុច (ក) ហើយនិង២១ នៃវិធានផ្ទៃក្នុង។ ដោយមូលដ្ឋានទាំងនេះជំទាស់ទៅនឹងទស្សនៈសហចៅក្រមស៊ើបអង្កេតជាតិ អ៎! អន្តរជាតិ (សូមទោស) ដែលនៅក្នុងទស្សនៈរបស់លោកនោះ មិនថា មិនស្ថិតនៅក្រោមសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទេ ក្នុងការបញ្ចេញទស្សនៈនេះ ហើយ (ខ) មិនមែនជាផ្នែកមួយ ឬទាក់ទិនទៅនឹងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលត្រូវសួរថាតើ មាស មុត នោះ ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់

អ.វ.ត.ក ឬក៏យ៉ាងណានោះទេ។ តើលោកយល់យ៉ាងម៉េចដែរ បាទ?

[១១:៥០:០៥]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកចៅក្រម។ សំណួរល្អណាស់។

ខ្ញុំសូមចាប់ផ្ដើមឆ្លើយទៅនឹងផ្នែកទី១ នៃសំណួរ។ បណ្ដឹងឧទ្ធរណ៍របស់ មាស មុត គឺជាបណ្ដឹងប្រឆាំងទៅនឹងការបញ្ជាក់អះអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះយុត្តាធិការរបស់ -- និយាយអំពីយុត្តាធិការមកលើរូបគាត់ គឺដោយយោងទៅលើវិធាន៧៤(៣)(ក)។ ចំណុចនេះ គឺថាមានការពន្យល់ល្អិតល្អន់នៅក្នុងកថា -- ពីកថាខណ្ឌ៧ ដល់១១ នៃការឆ្លើយតបរបស់យើងខ្ញុំ។ វិធាន៧៤(៣)(ក) គ្របដណ្ដប់ទៅលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការបញ្ជាក់អំពីយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការលើកម្មវត្ថុរបស់អ.វ.ត.ក។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវគោរពអំពីបញ្ហានេះ ប៉ុន្តែផ្ទុយទៅវិញ គាត់អះអាងថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នៅក្នុងការដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ហ្នឹង ដោយការបកស្រាយខុសទៅលើវិធាន៧៧(១៣)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះឥឡូវនេះ នៅចំពោះមុខអង្គជំនុំជម្រះហើយ ដែលត្រូវសម្រេចថាតើ មាស មុត ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬក៏អត់។ ចំណែកឯ -- នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជាក់អំពីយុត្តាធិការនេះ តែផ្នែកខ្លះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់តែប៉ុណ្ណោះ។

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះបានបកស្រាយយ៉ាងត្រឹមត្រូវអំពីវិធាន៧៧(១៣) ដែលថាគាត់មិនអាចកោះហៅ មាស មុត។ ហេតុដូច្នេះឯង វាមិនស្របនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មកលើគាត់ទេ។ ទោះបីជាសហចៅក្រមស៊ើបអង្កេត ថាដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ចាត់ទុកជាបានការ ឬក៏ដីកាដំណោះស្រាយទាំងពីរចាត់ទុកជាបានការក៏ដោយ គាត់បានបញ្ជាក់មិនច្បាស់លាស់ថា យុត្តាធិការ -- អំពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើ មាស មុត ដែរ។

[១១:៥២:៣០]

អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ដីកាដែលបញ្ជាក់មិនច្បាស់លាស់អំពីយុត្តាធិការរបស់អ.វ.ត.កនេះ បើបញ្ជាក់ច្បាស់លាស់ គឺអាចទទួលយកបាន ដោយអនុលោមតាមវិធាន៧៤(៣)(ក) គឺសេចក្ដីសម្រេចនៅក្នុងសំណុំរឿង០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតស្ដីអំពីសហឧក្រិដ្ឋកម្មរួម។ គឺឯកសារ D97/14/15 ពីកថាខណ្ឌ២៤ ដល់២៥។

ឥឡូវនេះ ការជំទាស់តវ៉ាទៅលើបញ្ហាយុត្តាធិការបុគ្គលរបស់យើងខ្ញុំនេះ វាមិនខុសគ្នាជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយនោះដែរ។ នៅពេលដែល ខៀវ សំផន គាត់ធ្វើការជំទាស់តវ៉ាទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលតែម្ដង ការជំទាស់តវ៉ារបស់គាត់មិនពាក់ព័ន្ធទៅនឹងយុត្តាធិការ ពាក់ព័ន្ធនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតចំពោះសិទ្ធិរបស់គាត់នៅក្នុងការដាក់ដីកាសន្និដ្ឋានជាស្ថាពរនោះ និង *ខ)* ភស្តុតាងដែលមិនមានជាភាសាបារាំង ជាភាសាខ្មែរ ឯកសារដែលមិនមានជាភាសាបារាំងនិងជាភាសាខ្មែរ។ (គ) គឺនិយាយអំពីតម្លាភាពនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺឯកសារ D427/4/15 កថាខណ្ឌ៦។

[១១:៥៤:០១]

ខុសពីការជំទាស់តវ៉ាបញ្ហាយុត្តាធិការបុគ្គល មិនមានការជំទាស់ណាមួយរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងទៅនឹងយុត្តាធិការបុគ្គលទៅលើរូបគាត់នោះទេ។ ផ្ទុយទៅវិញ គាត់លើកឡើងអំពីកំហុសនីតិវិធីដែលបានប្រព្រឹត្តឡើងដោយសហចៅក្រមស៊ើបអង្កេតទាំងពីរនៅក្នុងពេលគាត់បំពេញកិច្ចស៊ើបសួរ។

យើងខ្ញុំយល់ឃើញថា សិទ្ធិដ៏ទូលំទូលាយនៃការបណ្ដឹងឧទ្ធរណ៍ស្របតាមវិធាន៧៤(៣)(ក) ស្របទៅតាមវិធាន២១ ផងដែរនោះ គឺជាការចាំបាច់បំផុត។ ខ្ញុំលើកឡើងបែបនេះ ដោយសារសហចៅក្រមស៊ើបអង្កេតបានលើកឡើងថា បានលើកឡើងអំពីយន្តការដោះស្រាយដីកាដំណោះស្រាយនេះ គឺថាវាអត់មានចែងនៅក្នុងវិធានផ្ទៃក្នុង។ បណ្ដឹងឧទ្ធរណ៍របស់ មាស មុត លើកឡើងអំពីបញ្ហាដែលមិនអាចផ្សះផ្សាគ្នាបានពីសំណាក់អង្គជំនុំជម្រះសាលាដំបូងទេ។

ការមិនអនុញ្ញាតឱ្យ មាស មុត ប្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាព្យសនកម្មដែលមិនអាចផ្សះផ្សាបាន និងជាអចិន្ត្រៃយ៍ក្នុងការដកហូតសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញរបស់គាត់ និងទី២ ទៅនឹងការសន្មតថាគ្មានទោសទុកជាមុន ហើយនិង (ខ) គឺការការពារខ្លួនគាត់។ (គ) អំពីនីតិវិធីប្រឆាំងមកលើរូបគាត់។ (ឃ) និយាយអំពីការទទួលបានការការពារស្មើៗគ្នា នៅចំពោះមុខ អ.វ.ត.ក និង (ង) សិទ្ធិស្របតាមរដ្ឋធម្មនុញ្ញរបស់គាត់ក្នុងការទទួលបាននូវវិមតិសង្ស័យដែលត្រូវដោះស្រាយជាប្រយោជន៍ដល់រូបគាត់។

[១១:៥៥:៥៤]

ទី៣ យើងខ្ញុំសូមលើកឡើងថា ផលប្រយោជន៍នៃយុត្តិធម៌ ក៏ដូចជាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីត្រូវតែដោះស្រាយ ដោយផ្ដល់ជាប្រយោជន៍ដល់បណ្ដឹងឧទ្ធរណ៍របស់គាត់។ យើងខ្ញុំសូមលើក

ឡើងថាវាផ្គាំផ្គង វាមិនផ្គាំផ្គងទេ ដែលអង្គបុរេជំនុំជម្រះត្រូវពិចារណាបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា -- (សូមកែតម្រូវ) គឺវាផ្គាំផ្គងណាស់ បើទទួលបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ហើយបែរជាបដិសេធបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ទៅវិញនោះ។

អ៊ីចឹង អង្គបុរេជំនុំជម្រះត្រូវសម្រេច ថាតើដីកាដំណោះស្រាយទាំងពីរត្រូវចាត់ទុកជាបានការ ឬក៏យ៉ាងណា។ ហើយបើសិនជាចាត់ទុកដីកាដំណោះស្រាយបានការ ហើយបែរជាបដិសេធបណ្ដឹងឧទ្ធរណ៍នេះ គឺវាបដិសេធសិទ្ធិស្របទៅតាមរដ្ឋធម្មនុញ្ញរបស់ មាស មុត និងវាផ្ទុយទៅនឹងក្របខ័ណ្ឌគតិយុត្តសម្រាប់តុលាការនេះហើយ។

[១១:៥៦:៥៤]

ចំណុចទី៤ យើងខ្ញុំមិនបានលើកឡើងអំពីកំហុសមិនអាចទទួលយកបាននោះទេ ពីព្រោះបញ្ហានេះ វាជាបញ្ហាចម្រុះគ្នា ពាក់ព័ន្ធទាំងអង្គហេតុ ទាំងអង្គច្បាប់។ អង្គបុរេជំនុំជម្រះបានពិចារណាថាបញ្ហាទាំងអស់នេះ គឺត្រូវលើកឡើងនៅក្នុងសវនាការ នៅពេលដែលលើកឡើងអំពីទម្ងន់ភស្តុតាងពាក់ព័ន្ធ។ យើងខ្ញុំយោទៅលើសេចក្ដីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ មេសា ២០១១។ ឯកសារ 427/1/30 កថាខណ្ឌ៤៦។ ដូច្នេះ ដោយសារតែយើងខ្ញុំជំទាស់តវ៉ាទៅលើការអនុវត្តច្បាប់ពីសំណាក់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺថាទោះជាក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាបានយល់ស្របជាច្រើន អំពីភាពអាចទទួលយកបាននៃសារណានៃបណ្ដឹងឧទ្ធរណ៍ ដែលយើងខ្ញុំបានលើកឡើងបញ្ហាជាច្រើនដាក់ចំពោះមុខអង្គបុរេជំនុំជម្រះដែលត្រូវតែដោះស្រាយបញ្ហាយើងខ្ញុំលើកឡើង។ ហើយជាលទ្ធផល យើងខ្ញុំចំណាយប្រហែលជាមួយភាគបីនៃចំនួនទំព័រសារណាទាំងអស់ និយាយអំពីភាពអាចទទួលយកបាន។ ហើយយើងខ្ញុំបន្តទៅនិយាយរឿងដដែលនេះ នៅផ្នែកបន្តបន្ទាប់ទៀត ដូចដែលខ្ញុំបានលើកឡើងនៅចំពោះមុខ អ.ប.ជ។

[១១:៥៨:៣៩]

សុំឆ្លើយទៅនឹងផ្នែកទី២នៃសំណួររបស់លោកចៅក្រម។ មូលដ្ឋាន (ក) និងមូលដ្ឋានសំអាងហេតុ (ខ) នៃបណ្ដឹងឧទ្ធរណ៍របស់យើងខ្ញុំនេះ គឺវាពាក់ព័ន្ធគ្នា មិនមែនសហចៅក្រម -- មិនមែនតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការបកស្រាយវិធាន៧៧(១៣) នេះទេ។ យើងខ្ញុំសូមលើកឡើងថា បើសិនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចាត់ទុកជាបានការ ឬក៏ទាំងពីរចាត់ទុកជាបានការ។ យើងខ្ញុំស្នើសុំឱ្យអង្គបុរេជំនុំជម្រះអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់

ចោទ។ ប្រសិនជា-- ដោយសារតែសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ហើយច្បាប់អនុញ្ញាតអ៊ីចឹង នេះជា ឬ-- ហើយបើសហចៅក្រមស៊ើបអង្កេតអាចចេញដីកាដំណោះស្រាយតែមួយ ដូច្នេះយើងខ្ញុំយល់ឃើញថា បើយល់យ៉ាងនេះ គេអាចចាត់ទុកថាយើងខ្ញុំជាអ្នកខុសទៅវិញទេ។ បើយើងខ្ញុំជាអ្នកខុស តាមដែលខ្ញុំយល់ជាភាសាបារាំងនោះ ក្នុងរឿងស្មុគស្មាញបែបនេះ អ៊ីចឹងយើងមានសហចៅក្រមស៊ើបអង្កេតពីរ ហើយយើងខ្ញុំដឹងថាវាអាចមានលទ្ធភាពចេញដីកាដំណោះស្រាយពីរបែបនេះ។ ហើយម្នាក់ៗ បើគាត់មិនមានច្បាប់អនុញ្ញាត គាត់ត្រូវចេញតែដីកាដំណោះស្រាយតែមួយទេ មិនចេញពីរអ៊ីចឹងទេ។ គឺខ្ញុំយល់ឃើញថា សហព្រះរាជអាជ្ញាអាចមានកំហុស។ ហើយខ្ញុំសូមលើកឡើងម្តងទៀត កាលដែលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយដល់ទៅពីរអ៊ីចេះ វាមិនខុសអីទេ។ បើគាត់ចេញដីកាដំណោះស្រាយតែមួយ ពេលហ្នឹងគឺថាគាត់នឹងនិយាយពីប្រវត្តិសាវតារ និយាយពីអង្គហេតុ គាត់នឹងជ្រើសរើសយកអង្គហេតុទាំងអស់ ដែលគាត់យល់គ្នាយកមកនិយាយមក គាត់ចេញដីកាដំណោះស្រាយតែមួយបានបាត់ហើយ។ អ៊ីចឹង ចៅក្រមណាដែលគាត់មានសំអាងហេតុហ្នឹង វាមិនគ្រប់គ្រាន់តិចតួច គាត់អាចសម្រេចតាមចៅក្រមដែលគាត់មានសំអាងហេតុច្រើនជាង។

[១២:០១:៣៤]

ធម្មតា គឺយើងមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ មានដីកាលើកលែងការចោទប្រកាន់។ នៅចុងបញ្ចប់ៗនៃការវិភាគរបស់គាត់ម្នាក់ៗ គាត់ក៏ចេញសេចក្តីសម្រេចថា ម្នាក់សម្រេចថាលើកលែងការចោទប្រកាន់។ ចៅក្រមម្នាក់ទៀត សម្រេចថាត្រូវតែបញ្ជូនរឿងទៅជំនុំជម្រះ។ ហើយគាត់ត្រូវ -- ម្នាក់ៗត្រូវតែយកវិមតិសង្ស័យត្រូវបានជាផលប្រយោជន៍ដល់ជនជាប់ចោទនេះ យកមកបកស្រាយស្របទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ស្របទៅតាមកិច្ចព្រមព្រៀង អ.វ.ត.ក, ច្បាប់បង្កើត អ.វ.ត.ក។ ពួកគាត់នឹងមិនចេញដីកាលើកលែងការចោទប្រកាន់អ៊ីចឹងទេ។ អ៊ីចឹង ទោះបីគាត់មានជំហរខុសគ្នាខ្លះក៏ដោយ ក៏ប៉ុន្តែគាត់នឹងលើកហេតុផល ហើយក៏សម្របសម្រួលហេតុផលរបស់គាត់ ហើយគាត់ក៏ត្រូវយល់ស្របគ្នាក្នុងផ្នែកណាមួយដើម្បីចេញតែដីកា -- ចេញដីកាដំណោះស្រាយតែមួយ។

អ៊ីចឹងបើមេធាវីការពារក្តី យើងខ្ញុំនេះជាអ្នកខុសទៅវិញនោះ! ហើយបើគាត់បំពេញកិច្ចខុសគ្នាចេញសេចក្តីសម្រេចខុសគ្នា វាមិនមាននឹងខុសនោះទេ។ អ៊ីចឹងហើយបានមានបញ្ហានៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ហើយ អ៊ីចឹងហើយបានជាគាត់មានលទ្ធភាពឱ្យគាត់ចេញដីកាពីរ ហើយក៏អង្គបុរេជំនុំជម្រះក៏មានលទ្ធភាពក្នុងការដោះស្រាយវិវាទនេះផងដែរ។

អ៊ីចឹងទោះបីចេញដីកាដំណោះស្រាយតែមួយក្តី ចេញដីកាដំណោះស្រាយពីរបែបនេះក្តី គឺថាអង្គបុរេជំនុំជម្រះជាចុងក្រោយបំផុតនោះ ត្រូវតែអនុវត្តគោលការណ៍នៃវិមតិសង្ស័យនេះ។ ដោយសារតែសហចៅក្រមស៊ើបអង្កេតហ្នឹង គាត់មានឋានៈស្មើគ្នា។ ហើយគាត់យកគោល -- ហើយអង្គបុរេជំនុំវិញ គឺថាយកគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ប្រាកដជាអង្គបុរេជំនុំជម្រះសម្រេចទទួលយកដីកាលើកលែងការចោទប្រកាន់នេះហើយ។

[១២:០៤:១៤]

ដូច្នេះគឺថា គោរពទៅតាមគោលការណ៍វិមតិសង្ស័យហ្នឹងបានជាប្រយោជន៍ជនជាប់ចោទ ជាគោលការណ៍ដ៏ត្រឹមត្រូវ។ ឥឡូវនេះ គឺថាយើងមានលទ្ធភាពបញ្ហាបច្ចេកទេស ដែលសហចៅក្រមជាតិ និងអន្តរជាតិ ដូចជាចៅក្រមអន្តរជាតិដែលខ្ញុំយល់ស្របជាមួយនឹងការវិភាគចុងក្រោយ ពីព្រោះដោយសារយើងក៏ចៅក្រមឯករាជ្យ។ ពេលនោះ ក៏បញ្ហានឹងមកដល់អង្គបុរេជំនុំជម្រះ។ ក្នុងករណីនេះ គឺអង្គបុរេនឹងត្រូវប្រើគោលការណ៍និយាយពីវិមតិសង្ស័យបានជាប្រយោជន៍មកជនសង្ស័យ ហើយយើងនឹងត្រូវអនុវត្តទៅតាមនោះ។ ខ្ញុំយល់ថា អាចនឹងឆ្លើយសំណួរទៅនឹងសំណួរលោកចៅក្រម ខ្ញុំសូមបន្តទៅខាងមុខបន្តិចទៀត។ លោកចៅក្រមបានសួរអំពីមូលដ្ឋានច្បាប់ កាលចម្លើយរបស់លោក មាស មុត ទាក់ទងទៅនឹងគោលការណ៍វិមតិសង្ស័យនេះ គឺថាទោះបីជាការអនុវត្តគោលការណ៍វិមតិសង្ស័យនេះក៏ដោយ គឺថានេះគឺថាធ្វើឱ្យ--

[១២:០៥:៣៦]

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

*(គ្មានការបកប្រែ)*

**លោក ម៉ៃខល ការណាវ៉ាស៖**

សូមអភ័យទោសលោកចៅក្រម។ ដោយសារការងារច្រើនពេក ខ្ញុំច្រឡំ សូមអភ័យទោស។

ខ្ញុំនៅឈរដដែល--

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

ខ្ញុំនឹងចោទសំណួរបន្ទាប់នេះ ពេលក្រោយ។ ដោយសារយើងត្រូវចូលសវនាការសម្ងាត់។

**លោក ម៉ៃខល ការណាវ៉ាស៖**

ខ្ញុំសូមអនុញ្ញាតឱ្យដោះស្រាយបញ្ហាហ្នឹង នៅក្នុងនីតិវិធីអសាធារណៈ ប៉ុន្តែទោះជាយ៉ាងណាក្តី

បើសិនជាអង្គជំនុំជម្រះសម្រេចខុសពីហ្នឹងក៏បាន។

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

លោកមេធាវី ចង់ឱ្យខ្ញុំសួរឥឡូវ ឬក៏យ៉ាងម៉េច?

[១២:០៦:៣៣]

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំចង់បាននីតិវិធីជាអសាធារណៈ ប៉ុន្តែបើសម្រេចខុសពីហ្នឹងក៏បាន។

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

បើអ៊ីចឹង បើលោកអត់មានជំទាស់អី គឺថាអាចខ្ញុំសួរឥឡូវហ្នឹង។

បាទ កាលពីថ្ងៃទី១៨ ឆ្នាំ២០១៩ ឯកសារ D266/13 លោកនិយាយថាសុំឱ្យធ្វើ ថាតើលោក មាស មុត គាត់អាចឆ្លើយតាមរយៈវីដេអូខន់ហ្វើរ៉ង់បានដែរ ឬក៏អត់? ហើយគាត់អាចសុំការអនុញ្ញាតទៅព្យាបាលនៅប្រទេសថៃដែរឬក៏អត់?

នៅត្រង់ចំណុចនេះ អង្គជំនុំជម្រះសូមបញ្ជាក់ដូចតទៅ៖ តើឥឡូវសព្វថ្ងៃនេះ គាត់មានប៉ាស្ព័រដែលមានសុពលភាពដែរឬទេ? ហើយសំណួរទី២ គឺថា តើបើគាត់ទៅប្រទេសថៃហ្នឹង គាត់មានបានគោរពថាត្រូវធ្វើយ៉ាងម៉េច ធ្វើឱ្យតុលាការយើងនេះទាក់ទងបានដែរឬទេ? ហើយឧទាហរណ៍ គាត់មានដែលបង្ហាញសំណុំឯកសារអីទាំងអស់ ដែលខាងតុលាការយើងហ្នឹងសុំដែរឬទេ? គឺយើងមានឯកសារយោងហ្នឹង គឺដូចឯកសារ D174 ទំព័រទី១១ និងឯកសារ D174/2។

[១២:០៨:០៨]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកចៅក្រម។ សូមអនុញ្ញាត សូមបញ្ជាក់ថា យើងទំនាក់ទំនងជាមួយកូនក្ដីរបស់យើងជារៀងរាល់អាទិត្យ ហើយគាត់បានត្រៀមខ្លួនសម្រាប់ពួកយើងខ្ញុំ។ ហើយខ្ញុំពិនិត្យឃើញថា សំណួរ ដូចសំណួរនេះត្រូវបានសួរដោយចៅក្រម បូឡេនឌ័រ រួចហើយ ថាតើគាត់ទៅប្រទេសថៃដោយមិនមានប៉ាស្ព័រសុពលភាពដូចម្ដេច? ព្រោះប៉ាស្ព័រគាត់ លិខិតឆ្លងដែនគាត់បានផុតសុពលភាព?

ចម្លើយសាមញ្ញ នៅសំឡូតគឺមានចំណុចឆ្លងកាត់ព្រំដែនពីកម្ពុជាទៅប្រទេសថៃ។ មិនបើកជាគ្រប់ពេលទេ ប៉ុន្តែ-- ហើយប្រជាជនងាយស្រួលនឹងឆ្លងកាត់ ដូចជាគេប្រើជាអត្តសញ្ញាណ គឺការដែលយើង ទាល់តែយើងទៅតំបន់ហ្នឹង ទៅកន្លែងមួយចំនួនមានកម្រិត គ្រាន់ថាមិនរឿងអ្វីខុសពីធម្មតាទេ

ដែលថា មាស មុត មុនដែលគេចោទ -- រងការចោទប្រកាន់នោះ ដូចចៅក្រម បូឡេនឌ័រ គាត់បានទៅប្រទេសថៃ ដើម្បីមូលហេតុសុខភាព ពីព្រោះគាត់ត្រូវការវះកាត់បេះដូងជាដើម ហើយគឺគាត់បានអនុញ្ញាតឱ្យទៅត្រឹមខេត្តមួយហ្នឹង ហើយត្រឡប់មកវិញ ហើយយើងត្រឡប់ទៅ -- គាត់ទៅដល់ប៉ៃលិន ហើយទៅដល់ព្រំដែន ហើយឆ្លងទៅ បើកបិទទៅតាមពេលវេលា គឺជារឿងផ្លូវការរបស់-- ធម្មតារបស់ការងារ គឺមិនចាំបាច់មានលិខិតប៉ាស្ព័រទេ។ ដូច្នេះ គឺថាគាត់អាចទៅប្រទេសថៃនៅកន្លែងនោះ ដើម្បីមូលហេតុសុខភាព ព្យាបាលសុខភាព។

[១២:១០:០២]

ឥឡូវនេះ នៅពេលៗនោះ នៅពេលមានលិខិតឆ្លងដែនដែលផុតរយៈពេល ផ្អែកតាមសំណួរដែលសួរ ដែលខ្ញុំបានទទួលកាលពីម្សិលមិញ ឥឡូវនេះគាត់មានលិខិតឆ្លងដែនថ្មី គឺឆ្នាំ២០១៦ ខ្ញុំមិនបានដឹងពីមុនទេ ហើយគឺនៅនឹងខ្លួនគាត់។ អាចនឹងធ្វើឱ្យការ មានការភាន់ច្រឡំដែលថា គាត់មិនបានប្រគល់លិខិតឆ្លងដែនទៅនគរបាលទេ គាត់កាន់នៅនឹងខ្លួនគាត់។ ហើយនៅក្នុងពេលនេះ ខ្ញុំសូមបញ្ជាក់ថា ថាគាត់ៗបានចូលរួម ហើយនិងឆ្លើយឆ្លងជាមួយពួកយើងខ្ញុំ ហើយនៅក្នុងកម្រិតណាមួយដែល បើគាត់មានការយល់ច្រឡំពីកាតព្វកិច្ចរបស់គាត់ ខ្ញុំនឹងអាចនឹងបន្ទោសទៅលើមេធាវីគាត់ មិនមែនលើគាត់ទេ ពីព្រោះដោយសារគាត់មានវ័យចំណាស់។ គាត់អាចនឹងភ្លេចពេលវេលាដែលគាត់ទទួលដំណឹង។ ឥឡូវនេះគាត់បានទទួលលិខិតឆ្លងដែនថ្មី ហើយនិង ហើយមានការខុសគ្នារវាងអ្វីដែលគាត់មិនយល់ហ្នឹង គឺថាមេធាវីរបស់គាត់ គឺអាចនឹងជួយពន្យល់ មិនមែនលោក មាស មុត ទេ។ ដោយសារថាគាត់ចូលរួមយ៉ាងសកម្ម និងជាមួយមេធាវីការពារក្តី ក្នុងការពិនិត្យឯកសារជាមួយគ្នា។ ហើយគាត់មិនមានបញ្ហាអ្វីក្នុងការប្រគល់ជូនលិខិតឆ្លងដែនរបស់គាត់ទេ។ ដូចខ្ញុំបានកត់សម្គាល់នៅក្នុងការគ្រាអាសន្ន គាត់ត្រូវទៅប្រទេសថៃដើម្បីបញ្ហាព្យាបាលសុខភាព ដោយមានមូលហេតុច្បាស់លាស់។

ទោះបីជានៅក្នុងព្រំដែនពីមុននឹងក្តី គាត់មិនមានប៉ាស្ព័រសុពលភាព ក៏គាត់អាចទៅបាន។ អ៊ីចឹងគាត់អាចនឹងធ្វើបែបនោះបានជាបន្ត អាចនឹងជូនដំណឹងមកតុលាការ។ ហើយខ្ញុំសូមជម្រាបថា គឺថាអាចនឹង គាត់បានត្រៀមខ្លួនវត្តមាន គាត់នឹងមិនទៅណាទេ ហើយគាត់បានមានការប្តេជ្ញាចិត្តថានឹងសហការជាមួយនឹងកិច្ចរបស់តុលាការ ហើយបើមានអ្វីខកខាន យើងអាចនឹងបន្ទោសទៅមេធាវីជាតិ។

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

បាទ សូមអរគុណ។ ខ្ញុំស្តាប់ឮថា កូនក្តីរបស់លោកហ្នឹងនឹងប្រាប់ពីការធ្វើដំណើរផ្សេងៗ នៅ

ពេលអនាគត មែនទេ?

**លោក ម៉ៃខល កាណាវ៉ាស៖**

*(គ្មានការបកប្រែ)*

**ចៅក្រម អូលីវីយេ បូវ៉ាល្លេត៖**

បាទ សូមអរគុណ។ ឥឡូវ ខ្ញុំប្រគល់វេទិកាជូនលោកចៅក្រម បាក់។

[១២:១៣:២១]

**ចៅក្រម កាង ជីនបាក់៖**

*(គ្មានការបកប្រែ)*

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គបុរេ៖**

បាទ អត់ឮ។

[១២:១៤:២១]

**ចៅក្រម កាង ជីនបាក់៖**

បាទ ប្រហែលជាឮវិញហើយ លោកប្រធាន។

បាទ សូមចាប់ផ្តើម ខ្ញុំនឹងរំឭក។ សហមេធាវី មាស មុត អះអាងថា ចម្លើយរបស់គាត់ហ្នឹង គឺថាសហចៅក្រមស៊ើបអង្កេតជំទាស់ក្នុងការកំណត់យុត្តាធិការបុគ្គល ដោយមិនបានលើកពីភាពប្រាកដនៃនីតិវិធី ហើយបានលើកពីការវិមតិសង្ស័យក្នុងអង្គហេតុ ហើយសហមេធាវីបាននិយាយថា សហចៅក្រមស៊ើបអង្កេតបានប្រើវិធីដូចគ្នា ដើម្បីវិភាគ វាយតម្លៃ ហើយក៏បានឈានដល់ការសម្រេចកត្តាអង្គហេតុដែលមានវិមតិសង្ស័យ ក៏ត្រូវអនុវត្តគោលការណ៍វិមតិសង្ស័យបានជាផលប្រយោជន៍ជនជាប់ចោទ។ នេះជាទឡ្ហីករណ៍របស់មេធាវីការពារក្តី ថាតើសហព្រះរាជអាជ្ញាអន្តរជាតិមានចម្លើយអ្វីទៅនឹងសំណួរនេះ?

[១២:១៥:២៥]

**លោកស្រី ប្រេនដា ហូលិស៖**

សូមអរគុណលោកចៅក្រម។ មុននឹងចូលដល់ខ្លឹមសារសារធាតុនៃសំណួរ សូមបញ្ជាក់ថា យើងមិនយល់ស្របដែលថាសហចៅក្រមស៊ើបអង្កេតទាំងពីរវាយតម្លៃភស្តុតាងដូចគ្នា ប្រើប្រាស់កត្តាដូចគ្នា

នោះទេ គឺខុសពីហ្នឹង។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺថាប្រើសំណុំរឿងទាំងពីរ គឺទាំងមុនឆ្នាំ២០១១ ហើយនិងក្រោយ គឺពិនិត្យបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ទម្រង់នៃការទទួលខុសត្រូវ ហើយបានធ្វើការវាយតម្លៃទៅលើគ្រប់វត្ថុតាងនៅក្នុងអង្គហេតុ។ ហើយម្យ៉ាងវិញទៀត គឺថាច្បាស់មើលមិនបានពិចារណាទៅលើភាគច្រើនដ៏លើសលុបនៅក្នុងរឿងដែលច្រើន ក្រោយដែលដាក់ក្រោយឆ្នាំ២០១២ -- អ៎! ២០១១ ទេ ប៉ុន្តែមិនថាផ្ទុះបញ្ជាំងថា ភស្តុតាងភាគច្រើនដែលមានពីមុនថ្ងៃ២៩ មេសា ២០១១ នោះទេ។

[១២:១៦:៣៣]

ដីកាលើកលែងការចោទប្រកាន់មិនបានប្រើភស្តុតាងទាំងនេះ ហើយមិនបានលើកឡើងពីទម្រង់ការទទួលខុសត្រូវ បទឧក្រិដ្ឋដែលបានប្រព្រឹត្ត ហើយមិនបានកំណត់បទចោទទៅតាមអង្គហេតុនោះទេ។ ដូច្នេះហើយ គឺថាយើងមិនអាចបញ្ជាក់ ដូចមេធាវីការពារក្តីបានទេ នៅក្នុងសេចក្តីសន្និដ្ឋាននោះ គឺថា គឺវាមានដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា ដែលមាននីត្យានុកូលភាពដូចគ្នា ជំហររបស់យើងខ្ញុំគឺថា ដីកាលើកលែងការចោទប្រកាន់មិនមានសុពលភាពតាមផ្លូវច្បាប់នោះទេ គឺថាមានកំហុសឆ្គងធ្ងន់ខាងផ្លូវច្បាប់។

ចូលទៅដល់ខ្លឹមសារសារធាតុនៃសំណួរ។ ទោះបីជាអង្គបុរេជំនុំជម្រះទាក់ទងទៅនឹងភាពមិនប្រាកដនៃនីតិវិធីឬក៏អង្គហេតុមិនច្បាស់លាស់ យើងត្រូវពិនិត្យមើលឯកសារ ហើយយើងមើលអង្គហេតុដែលថាអង្គបុរេត្រូវពិនិត្យមើលដំណាក់ពីរទៅតាមស្ថានភាពពីរ។ ទី១ គឺការប្រើមុខងារជាតុលាការជាន់ខ្ពស់ ថាតើដីកាដំណោះស្រាយទាំងពីរហ្នឹង តើមានកំហុសឆ្គងៗអង្គច្បាប់ទាំងពីរដីកាហ្នឹង ឬក៏តែមួយ? ថាតើមានកំហុសឆ្គងអង្គហេតុដែលអាចនឹងធ្វើឱ្យមានកំហុសឆ្គោយយុត្តិធម៌នៅក្នុងណាមួយហ្នឹងដែរឬទេ? ហើយនិងពិនិត្យមើលទៅលើកត្តាអំពីយុត្តាធិការបុគ្គល។ ដូច្នេះហើយគឺអង្គបុរេជំនុំជម្រះនៅក្នុងដំណាក់កាលទី១ អាចសម្រេចបញ្ហាហ្នឹងបាន។ ចំណុចបន្ទាប់មក គឺមិនកើតមានឡើងទេ ប៉ុន្តែបញ្ហាសារធាតុហ្នឹង គឺថាកើតឡើងនៅក្នុងដំណាក់កាលទី២។ ដំណាក់កាលទី២ ដែលយើងទទួលបាននេះ គឺថាតើអ្វីជាផលវិបាកនៃការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ មិនមែនជាខ្លឹមសារនៃដីកាដំណោះស្រាយ? ថាតើអ្វីជាផលវិបាកនៃសេចក្តីសម្រេចនោះចំពោះអង្គបុរេជំនុំជម្រះ? នេះជាបញ្ហានីតិវិធី មិនមែនជាបញ្ហាអំពីវិមតិសង្ស័យនូវអង្គហេតុនោះទេ។

[១២:១៨:៥២]

ដូច្នេះយើងសូមជម្រាបថា នៅក្នុងរឿងក្តីចំពោះមុខអង្គបុរេជំនុំជម្រះនោះ មិនតម្រូវឱ្យមាន

សំឡេងភាគច្រើនលើសលុបទេ ដែលថាចៅក្រមបីរូប មានសេចក្ដីសម្រេចមួយ ហើយមួយផ្សេងនោះទេ គឺថាអាចពីរស្មើគ្នាក៏ដោយ ក៏មិនអាចនឹងលើកឡើងអំពីបញ្ហាវិមតិសង្ស័យនេះដែរ។ ទោះបីតែនៅក្នុងករណីការមតិយល់ជំទាស់នោះក៏ដោយ ប៉ុន្តែយើងពិនិត្យមើលតែអ្វីជាផលវិបាកនៃការសម្រេច ការកំណត់ទៅលើបណ្ដឹងឧទ្ធរណ៍នេះ។ នៅក្នុងដំណឹង -- ដំណាក់កាលនីតិវិធីឧទ្ធរណ៍នេះចប់ យើងត្រូវសម្រេចថាតើនីតិណាមួយដែលយើងត្រូវសម្រេចបណ្ដឹងឧទ្ធរណ៍ហ្នឹង ត្រូវប្រើនីតិវិធីណាមួយដើម្បីដោះស្រាយបញ្ហាដីកាដំណោះស្រាយពីរដែលផ្ទុយគ្នានេះ។ នេះជាបញ្ហានីតិវិធីនេះ គឺថាអាចនឹងត្រូវដោះស្រាយ និងត្រូវពិនិត្យមើលកិច្ចព្រមព្រៀង អ.វ.ត.ក ហើយច្បាប់បង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង ហើយនិងយុត្តិសាស្ត្រនៃអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះនេះ។

[១២:២០:១៩]

នៅក្នុងដំណាក់កាលទី២នេះ មិនមានសំណួរអ្វីទាក់ទងទៅមូលដ្ឋានដែលថាសហចៅក្រមស៊ើបអង្កេតដែលថា ឆន្ទានុសិទ្ធិរបស់គាត់ត្រូវអនុវត្តដូចម្ដេចនោះទេ គឺថាមិនមានសំណួរថា ឆន្ទានុសិទ្ធិពីរខុសគ្នា ឬមិនខុសគ្នាដូចម្ដេចហ្នឹង វាលែងចោទជាបញ្ហានៅនេះហើយ។ អ៊ីចឹងឆ្លើយទាក់ទងទៅនឹងបញ្ហានីតិវិធីដែលអង្គបុរេត្រូវដោះស្រាយនៅក្នុងដំណាក់កាលទី២ នៅពេលដែលចប់ដំណើរការឧទ្ធរណ៍នេះ ហើយត្រូវពិនិត្យមើលប្រភពច្បាប់ដែលខ្ញុំបានយោងទៅហ្នឹង ចម្លើយគឺច្បាស់បើមានដីកាដំណោះស្រាយពីរនៅមាននៅឡើយ តើសេណារីយ៉ូអ្វីដែលបង្កើតឡើងនូវស្ថានភាពនោះ? ករណីនឹងត្រូវបានបញ្ជូនទៅជំនុំជម្រះ ហើយយើងខ្ញុំនឹងផ្ដល់ទឡ្ហីករណ៍ដ៏លម្អិត ថាតើអ្វីដែលនឹងត្រូវពិនិត្យពិចារណា ថាតើត្រូវមានសំឡេងភាគច្រើនលើសលុបដែរឬអត់? អ៊ីចឹងគឺថាបញ្ហានេះ គឺមិនមានបញ្ហាទេ គឺគ្រាន់តែបញ្ហាហ្នឹងនាំមកអង្គបុរេ គឺអង្គបុរេត្រូវពិនិត្យមើលតែផលវិភាគ ថាតើត្រូវសម្រេចដូចម្ដេច? ថាតើដីកាដំណោះស្រាយពីរនេះ គឺយើងត្រូវសម្រេចដោយផ្អែកលើច្បាប់ ហើយច្បាប់នៅទីនេះ តើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅមានសុពលភាព គឺថាផ្អែកលើបញ្ហានីតិវិធី គឺត្រូវទៅមុខ។

[១២:២២:០៣]

មិនអាស្រ័យ ផ្អែកទៅលើការជំនុំជម្រះយុត្តិធម៌សម្រាប់ជនជាប់ចោទនោះ គឺថាត្រូវបានគោរពនូវពេលជំនុំជម្រះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសិទ្ធិរបស់ភាគីពាក់ព័ន្ធដទៃទៀតត្រូវការពារដែរ ដូចជាសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិពិនិត្យភស្តុតាង ហើយនិងសិទ្ធិទទួលបានការជំនុំជម្រះដោយជនជាប់ចោទផងដែរ។ ដូច្នេះការនីតិវិធីនេះ គឺមិនត្រូវអនុវត្តទេ ចំពោះគោលការណ៍វិមតិសង្ស័យបានជា

ប្រយោជន៍ដល់ជនជាប់ចោទនោះ។ ហើយអាចនឹងករណី អាចនឹងជាករណីសង្ស័យ គឺផ្អែកទៅលើច្បាប់សារធាតុ គឺមិនស្ថិតនៅក្នុងអ្វីជាបញ្ហានីតិវិធីចំពោះមុខអង្គបុរេនេះទេ។

អ្វីដែលខ្ញុំនឹងជម្រាបជូនបន្ថែមហ្នឹងគឺថា ដើម្បីអនុវត្តនូវគោលការណ៍វិមតិសង្ស័យនេះ គឺថាតើត្រូវឱ្យមានបញ្ហាអ្វីទាក់ទងទៅនឹងនីតិវិធីហ្នឹង គឺថាតើវាមានករណីត្រូវមានអត្ថបទច្បាប់ ត្រូវតែបើកចំហឱ្យមានការបកស្រាយ។ ពេលនោះ គឺថាយើងអាចនឹងអនុវត្តគោលការណ៍វិមតិសង្ស័យនេះ ប៉ុន្តែក្នុងករណីនេះ គឺថាមិនមានសំឡេងភាគច្រើនដាច់ខាត គឺដើម្បីហាមទេ គឺនឹងត្រូវប្រឈមមុខនោះ។ ដូច្នេះបញ្ហានេះ វាជាការកត្តាសំខាន់ ដើម្បីធានានូវភាពយុត្តិធម៌ដោយផ្អែកសច្ចធារណ៍និរទោស ហើយនិងបន្ទុកនៃការផ្តល់ភស្តុតាងហួសពីវិមតិសង្ស័យ ក៏មិនអនុវត្តនៅក្នុងករណីពេលនេះដែរ។

[១២:២៣:៥៥]

**ចៅក្រម កាង ជីនបាក់៖**

សូមអរគុណ។ ខ្ញុំសូមសួរបន្តទៅទៀត។ ខ្ញុំបានឮអំពីលោកស្រីបានដកស្រង់សេចក្តីសម្រេចតុលាការកំពូល គឺថាដែលគាត់ស្នើសុំឱ្យមានការដោះលែងភ្លាមៗ ហើយលោកស្រីបានលើកឡើងថាមិនមានបញ្ហាប្រើគោលការណ៍វិមតិសង្ស័យនោះទេ នៅក្នុងរឿងសេចក្តីសម្រេច ខៀវ សំផន។ នៅក្នុងករណីគោលការណ៍វិមតិសង្ស័យនេះ ទាល់តែមានករណីចន្លោះ ខ្វះចន្លោះនៃច្បាប់ ទើបអាចនឹងយកមកប្រើបាន។ តាមអ្វីដែលខ្ញុំយល់ គឺអង្គជំនុំជម្រះតុលាការកំពូល គឺមិនបានដកស្រង់ទាំងស្រុងអំពីការអនុ-វត្តគោលការណ៍វិមតិសង្ស័យនៅក្នុងដំណាក់កាលនីតិវិធីទេ នៅក្នុងករណីដែលមានកំហុសឆ្គងអង្គហេតុនោះ គឺថា ភាគីនីមួយៗ យល់ថា គឺថាអាចនឹងជាភាពស្មុគស្មាញនៅក្នុងក្រមព្រហ្មទណ្ឌអន្តរជាតិ ច្បាប់អន្តរជាតិ។ ហេតុអីបានលោកស្រី អះអាងខុសពីនេះទៅវិញ?

**លោកស្រី ប្រេនដា ហូលិស៖**

បញ្ហានេះ ដែលថាត្រូវអនុវត្តនោះក្នុងសេណារីយ៉ូជាច្រើន ប៉ុន្តែមើលអនុវត្ត យើងអនុវត្តនៅក្នុងដំណាក់កាលនីតិវិធីដែរឬអត់? ហើយយើងថាតើមានការសង្ស័យ ឬវិមតិសង្ស័យអំពីច្បាប់ដែលត្រូវអនុវត្តទេ? ដូច្នេះថាតើមានភាពពាក់ព័ន្ធដែរឬអត់? ប៉ុន្តែក្នុងករណីយើងហ្នឹង មិនមានភាពសង្ស័យទេ។ តើនឹងមានអ្វីកើតឡើង មានផលវិបាកអ្វី បើមានដីកាពីរផ្ទុយគ្នាបែបនេះ? មួយត្រូវបញ្ជូនទៅតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ឬដែរឬយ៉ាងណា? នេះគឺជាស្ថានភាពពិសេសរបស់តុលាការនេះ ដោយសារយើងមានសហចៅក្រមស៊ើបអង្កេតពីរ ដែលយើងទទួលបានស្ថានភាពជាលើកដំបូងក្នុងការបក

ស្រាយអំពីគោលការណ៍នេះ។ ក្នុងករណីកម្រណាស់នៅក្នុង -- យកមកអនុវត្តនៅក្នុងដំណាក់កាលនីតិវិធី។

[១២:២៦:១៨]

**ចៅក្រម កាង ជីនបាក់៖**

ឥឡូវនេះខ្ញុំអរគុណ ខ្ញុំនៅមានសំណួរបន្ទាប់ទៀត។

លោកស្រីអះអាងថា មាត្រា៧ កថាខណ្ឌ៤ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា នូវគោលការណ៍យ៉ាងច្បាស់លាស់ទាក់ទងទៅនឹងអ្វីដែលត្រូវធ្វើ តើអង្គបុរេជំនុំជម្រះអាចមានលទ្ធភាពក្នុងការដោះស្រាយការខ្វែងមតិរវាងសហចៅក្រមស៊ើបអង្កេត ឬក៏សហព្រះរាជអាជ្ញានាការឆ្លើយតបទៅនឹងមេធាវីការពារ? កថាខណ្ឌ២៦ ក្នុងករណីនេះបានបញ្ជាក់ថា កិច្ចស៊ើបសួរ ឬក៏ការស៊ើបអង្កេត ឬក៏ការចោទប្រកាន់ត្រូវបន្តទៅមុខ។ អ្វីដែលខ្ញុំយល់ថា ការអះអាងពីគោលនយោបាយរបស់លោកស្រីនៅក្នុងករណីនេះ គឺថា មានន័យថា ការផ្ទេរដីកាដំណោះស្រាយ ការចោទប្រកាន់ទៅអង្គជំនុំជម្រះ ហើយនិងសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីជម្រះ។

**លោកស្រី ប្រេនដា ហូលិស៖**

ដូច្នេះ វាផ្អែកទៅលើយុត្តិសាស្ត្រនៃតុលាការនេះ គឺថាមិនចោទជាបញ្ហាអ្វីនោះទេ គឺបើមានដីកាបញ្ជូនទៅជម្រះហើយ មិនមានសំឡេងភាគច្រើនដើម្បីទប់នោះទេ ដូច្នេះគឺថាអាចនឹងរឿងក្តី នឹងត្រូវបញ្ជូនទៅមុខដើម្បីនីតិវិធីបន្ទាប់។ ហើយកិច្ចស៊ើបសួរ គឺថាចប់ហើយ គឺត្រូវអង្គជំនុំជម្រះសាលាដំបូងបានទទួល។

[១២:២៨:០១]

**ចៅក្រម កាង ជីនបាក់៖**

អ៊ីចឹងគឺថា ក្នុងករណីមួយតាមអត្ថន័យនោះ គឺថា -- ប៉ុន្តែភាសានៅក្នុងច្បាប់ចែងដូចម្តេច?

**លោកស្រី ប្រេនដា ហូលិស៖**

*(គ្មានការបកប្រែ)*

**ចៅក្រម កាង ជីនបាក់៖**

ការស៊ើបអង្កេតរាប់បញ្ចូលទាំងការបញ្ជូនសំណុំរឿង។

**លោកស្រី ប្រេនដា ហូលិស៖**

គឺតាមពិតហើយ គឺការបញ្ជូនរឿងតាមយុត្តិសាស្ត្រ។

**ចៅក្រម កាង ជីនបាក់៖**

តាមពិតគឺដីកាដំណោះស្រាយនិយាយថា បញ្ចប់កិច្ចស៊ើបសួរ។

**លោកស្រី ប្រេនដា ហូលិស៖**

ខ្ញុំមិនចង់និយាយពីអ្វីដែលយើងបានទទួលបានទេ ប៉ុន្តែនៅពេលដែលការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងដោយដីកាបញ្ជូននេះ គឺថាបើយើងមើលវិធានផ្ទៃក្នុង៧៩ កថាខណ្ឌ១ និយាយអំពីដីកាបញ្ជូនរឿងទៅជម្រះ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដែលគាំទ្រជំហររបស់យើងដែលថា ដីកាបញ្ជូនរឿងទៅជម្រះត្រូវទៅមុខ លើកលែងតែមានសំឡេងភាគច្រើនលើលុបរាវាំង។

[១២:២៩:១៥]

**ចៅក្រម កាង ជីនបាក់៖**

សំណួរមួយទៀតទៅសហចៅក្រមជាតិ -- សហព្រះរាជអាជ្ញាជាតិ។ នៅក្នុងបណ្តឹងលោកអះអាងថា មានយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងការជំនុំជម្រះរឿងក្តី ០១ និងរឿង ០២ ដូចដែលលោកហ្នឹងបាន -- ជនរងគ្រោះបានច្រើនស្លាប់ ហើយនិងរងគ្រោះនៅក្នុងរបបខ្មែរក្រហមនេះ រាប់បញ្ចូលទាំងជនរងគ្រោះដែលបានស្លាប់ ហើយនិងទទួលរងទុក្ខនៅក្នុងកំពង់សោម នៅកោះដែលជាតំបន់ស្វយ័ត។ បញ្ហាឧក្រិដ្ឋនេះត្រូវចោទនៅក្នុងរឿងក្តី០០២ ហើយសហព្រះរាជអាជ្ញាអះអាងថា មិនមានចែងនៅក្នុងរឿងក្តី០០១, ០០២ ប៉ុន្តែមាន ០៣។ តើលោកអាចនឹងឆ្លើយបានដូចម្តេច?

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកចៅក្រម។

វាជាការពិតណាស់ គឺថាមានជនរងគ្រោះជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មានជនរងគ្រោះដោយផ្ទាល់ ដែលអ្នកខ្លះបានទទួលរងទុក្ខវេទនាលើរូបរាងកាយ លើស្មារតី សតិអារម្មណ៍ ដោយសារអំពើធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញជាច្រើនរូបភាព។ ហើយក៏នៅមានផងដែរ ជនរងគ្រោះជាច្រើនផ្សេងទៀត ដែលរងគ្រោះដោយប្រយោលពីអំពើឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យដ៏ខ្មៅងងឹតមួយនេះ។ ដោយសារវិសាលភាពនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម បានកើតឡើងនៅទូទាំងផ្ទៃប្រទេសកម្ពុជា និងដោយសារតែបក្សកុម្មុយនីស្តកម្ពុជា មិនបានលើកលែង ឬក៏

អត់ឱនឱ្យភូមិភាគណាមួយ ឱ្យតំបន់ណាមួយ ឬក៏សូម្បីតែភូមិដ៏តូចមួយ ក៏មិនត្រូវបានលើកលែងពីការគ្រប់គ្រង ការតាមដាន បញ្ជា និងការអនុវត្តឱ្យខានតែបាន នូវរាល់គោលនយោបាយរបស់បក្សកុម្មុយ-នីស្តកម្ពុជាដែលបានដាក់ចេញមកនោះ។ មានជនរងគ្រោះនៅគ្រប់ទីកន្លែង និងគ្រប់ភូមិភាគ និងគ្រប់តំបន់ នៅតាមស្រុក តាមឃុំ តាមភូមិ មិនថាប្រជាជនខ្មែរ មិនថាជនជាតិភាគតិច ឬក៏ជនបរទេស ក៏មិនអាចគេចផុតបានឡើយ។ ដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមានវិសាលភាពដ៏ធំទូលាយ ដែលកើតឡើងពាសពេញផ្ទៃប្រទេសនេះហើយ បានជាសហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យបានទទួលយុត្តិធម៌តាមរយៈសំណុំរឿងលេខ០០១ និង សំណុំរឿងលេខ០០២ទាំងមូល ដោយសារសំណុំរឿងទាំងពីរនេះ មានភាពជាតំណាងពេញលេញ ចំពោះវិសាលភាពនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងបរិបទនៃកម្ពុជាប្រជាធិបតេយ្យនៅទូទាំងប្រទេសកម្ពុជា។

[១២:៣២:៥០]

មានភស្តុតាងជាច្រើន និងក៏មានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានការស្តាប់ចម្លើយជនរងគ្រោះ ការស្តាប់ចម្លើយសាក្សីជាច្រើនផ្សេងទៀត មកពីគ្រប់ភូមិភាគ និងតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ដើម្បីចូលរួមក្នុងការជំនុំជម្រះលើបទចោទប្រកាន់នៅក្នុងសំណុំរឿងលេខ០០១ និងសំណុំរឿងលេខ០០២។ អាចនិយាយម្យ៉ាងទៀតបានថា ការជំនុំជម្រះសេចក្តីលើសំណុំរឿងលេខ០០១ និងលេខ ០០២ នេះគឺជាការស្វែងរកយុត្តិធម៌ជារួម ដែលមានភាពជាតំណាងជូនដល់ជនរងគ្រោះជាទូទៅសម្រាប់ប្រជាជនកម្ពុជាផង និងអ្នកដែលឈឺចាប់ចំពោះអំពើអមនុស្សធម៌ ដែលកើតមានឡើងក្នុងរបបនេះផងដែរ ព្រោះថា តុលាការមួយនេះមិនអាចលើកយកគ្រប់អង្គហេតុ គ្រប់បទល្មើសទាំងអស់យកមកធ្វើការកាត់សេចក្តីនោះទេ។ ជាក់ស្តែង បើយើងពិនិត្យមើលសូម្បីតែសហចៅក្រមស៊ើបអង្កេត ក៏បានធ្វើការកាត់បន្ថយវិសាលភាព ដោយដកចេញនូវអង្គហេតុដែលគាត់យល់ថាជាបទល្មើសជាច្រើន មិនយកមកចាត់ការ។ ឧទាហរណ៍ មានដូចជា ទីតាំងសម្លាប់មនុស្សស្ទឹងតូច ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២២ជាដើម។ ដោយសារតែមានភាពជាតំណាងនេះហើយ បានជាសហព្រះរាជអាជ្ញាជាតិបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនពីភាពតំណាងនៃសំណុំរឿង០០១ និង ០០២ នេះ។ សហព្រះរាជអាជ្ញាជាតិជឿជាក់ថា យើងទាំងអស់គ្នា--

[១២:៣៤:៣៨]

**ប្រធានអង្គបុរេ៖**

ផ្អាក សុំផ្អាក! សុំសម្រាកមួយនាទី ដើម្បីប្តូរស៊ីឌី។

*(សម្រាករយៈពេលខ្លី)*

សូមចាប់ផ្តើមបន្តដំណើរការ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្តទៀត។ សហព្រះរាជអាជ្ញាជាតិជឿជាក់ថា យើងទាំងអស់គ្នាពិតជាចង់បានណាស់នូវយុត្តិធម៌មួយដែលអាចប្រគល់ជូនដល់ជនរងគ្រោះគ្រប់ៗរូប មិនចង់ឱ្យរំលងសូម្បីជនណាម្នាក់ឡើយ ហើយមិនចំពោះតែជនរងគ្រោះដែលបានស្លាប់ ឬទទួលរងការឈឺចាប់នៅលើកោះ នៅសមុទ្រ ឬនៅតំបន់ស្វយ័តកំពង់សោមនោះទេ សូម្បីតំបន់ផ្សេងៗទៀត តាមដងទន្លេ តាមព្រំដែន ក៏គួរត្រូវបានយុត្តិធម៌ផងដែរ ប៉ុន្តែវាពិតជាមានសារៈសំខាន់ដែលយើងទទួលស្គាល់នូវការពិតមួយដែលថា កិច្ចខំប្រឹងប្រែងរបស់ អ.វ.ត.ក និយាយជារួម និងនិយាយដោយឡែក ការិយាល័យសហព្រះរាជអាជ្ញាបានចូលរួមនៅក្នុងសំណុំរឿងលេខ០០១ និងសំណុំរឿងលេខ០០២ ពិតជាមានភាពជាតំណាងពេញលេញចំពោះអាណត្តិ និងបេសកកម្មមួយច្បាស់លាស់ ដែលជាគោលគំនិតដំបូងនៃការបង្កើត អ.វ.ត.ក របស់យើងនេះ។ បាទសូមអរគុណ។

[១២:៣៦:៥១]

**ចៅក្រម កាង ជីនបាក់៖**

សូមអរគុណដែលសហព្រះរាជអាជ្ញាជាតិបានឆ្លើយ។ ឥឡូវនេះ ខ្ញុំសូមសួរសំណួរទៅមេធាវីការពារក្តី ខ្ញុំយល់ពីទឡ្ហីករណ៍របស់លោកហើយ ប៉ុន្តែខ្ញុំសួរសំណួរដំបូង។ បើខ្ញុំយល់មិនខុសទេ គឺថាអង្គបុរេជំនុំជម្រះមិនមានកាតព្វកិច្ចដើម្បីដោះស្រាយនេះទេ ហើយសហចៅក្រមស៊ើបអង្កេត គឺថាមិនមានកាតព្វកិច្ចដើម្បីស្វែងរកអំពីការរាំងស្ទះ អំពីនីតិវិធីតាមវិធាន៧២។ ម្យ៉ាងវិញទៀត នៅត្រង់ចំណុចនេះ សហចៅក្រមស៊ើបអង្កេតអាចជ្រើសរើសមិននាំយកករណីខ្វែងយោបល់គ្នា ថាតើ មាស មុត ស្ថិត ឬមិនស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ មកដាក់ចំពោះមុខអង្គបុរេ? ហើយសូមលោកបញ្ជាក់អំពីមូលដ្ឋាននៃការបកស្រាយរបស់លោកអំពីវិធានទាំងឡាយដែលគាំទ្រការអះអាងនេះ។ ខ្ញុំមិនត្រូវការឱ្យលោកយោងទៅច្បាប់ជាក់លាក់នោះទេ។

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកចៅក្រម។ នេះគឺជាផ្នែកមួយដែលជាចំណុចពិសេសដែលមាត្រា៤,៥ ហើយ

និងមាត្រា៧ ហើយមាត្រា២០ ហើយនិងវិធានផ្ទៃក្នុង ក៏បានផ្ដល់ឆន្ទានុសិទ្ធិទៅឱ្យសហចៅក្រមស៊ើបអង្កេត។ ឥឡូវនេះខ្ញុំនឹង -- ហើយឥឡូវនេះយើងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត។ បើសិនជាគាត់ធ្វើការជាមួយគ្នានៅក្នុងករណីនេះ គឺមាននៅក្នុងសំណុំរឿង ប៉ុន្តែមិនថា ដកខ្លួនចេញពីបញ្ហានោះទេ អាចនឹងជាការកំហុសដែលពួកគាត់ធ្វើការខុសច្បាប់នោះទេ ប៉ុន្តែពួកគាត់អាចនឹងព្យាយាមដោះស្រាយថាតើមានបញ្ហាអីដែលមិនអាចជួសជុលបាន បើសិនមានការខ្វែងគំនិតគ្នាហ្នឹង គឺថាអាចស្ថិតនៅក្នុងឯកសារមួយ។

[១២:៣៩:១៣]

ប៉ុន្តែអ្វីដែលយើងលើកឡើងនៅទីនេះ គឺថាយើងចង់ផ្ដល់ឯករាជ្យទាំងស្រុងដល់ចៅក្រមទាំងពីរ គឺថាពួកគាត់ស្មើគ្នា ស្មើភាពគ្នា។ គឺថាយើងពិនិត្យឃើញថា គាត់អាចនឹងពិនិត្យមើលតើ -- យើងមិនអាចបង្គាប់ថា ត្រូវដោះស្រាយបញ្ហាហ្នឹង ត្រូវតែស្រុះស្រួលគ្នានោះទេ មិនចាំបាច់បញ្ជូនមកអង្គបុរេជំនុំជម្រះទេ។ ប៉ុន្តែបញ្ហានេះគឺថា វាមិនអាចសម្រុះសម្រួលគ្នាបាន ទើបបានកើតជាករណីនេះ។ គឺអាចមានមូលហេតុផ្សេងទៀត។ ដូច្នេះ នៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយនិងក្នុងដំណាក់កាលចោទប្រកាន់ក៏ដោយ គឺថាបើមានការខ្វែងគំនិត គឺថាត្រូវបញ្ជូនមកអង្គបុរេ ហើយនិងត្រូវដោះស្រាយ ហើយក៏អាចដោះស្រាយនៅក្នុងពេលដំណាក់កាលស៊ើបអង្កេតរវាងពួកគាត់ដែរ។ អ៊ីចឹងគឺថា នៅក្នុងផ្នែកទី២ ដាច់ដោយឡែកដែលថា មានដីកាដំណោះស្រាយពីរខុសគ្នានេះ គឺធ្វើឱ្យអង្គបុរេជំនុំជម្រះដែលថាមិនស្ថិតជាកាតព្វកិច្ចរបស់អង្គបុរេជំនុំជម្រះទេ។ នៅក្នុងករណី អៀង សារី គឺនៅក្នុងឯកសារ D427/1/30 កថាខណ្ឌ២៧៤ នេះហើយជាស្ថានភាពមួយដែលយើងមានដីកាលែងការចោទប្រកាន់ ហើយនិងដីកាបញ្ជូនរឿងទៅជម្រះនោះ។ ហើយនៅក្នុងករណីនេះដែរ នៅពេលដែលយើងមានសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថាបកប្រែ -- បកស្រាយ វិធាន ៧៧(១៣) គឺថាដែលយើងលើកឡើងនៅក្នុងមូលហេតុ (ក) និង (ខ) របស់មូលដ្ឋានរបស់យើងខ្ញុំនោះ យើងឃើញហើយ យើងមិនយល់ស្របជាមួយហ្នឹងសហព្រះរាជអាជ្ញាអន្តរជាតិទេ ដែលគាត់បកស្រាយថា ដែលថាអង្គបុរេជំនុំជម្រះនោះគឺថាចាត់ទុកថាជាអង្គភាពដោះស្រាយបញ្ហាសារធាតុនោះ ប៉ុន្តែអ្វីដែលយើងយល់ថាអង្គបុរេជំនុំជម្រះនោះគឺខុសពីហ្នឹង គឺយើងត្រូវចាត់ទុកដីកាដំណោះស្រាយពីរដែលផ្ទុយគ្នាហ្នឹង ចាត់ទុកថាជាការខ្វែងគំនិតគ្នា។ នេះហើយជាអ្វីដែលមានចែងនៅក្នុងវិធាន៧២ នោះ។

[១២:៤១:៥៤]

នៅក្នុងវិធាន៧៧ ផ្អែកលើវិធាន៧២ គឺពេលវេលាគឺខុសគ្នា ដំណាក់កាលខុសគ្នា។ កិច្ចស៊ើបសួរត្រូវបានបញ្ចប់ ហើយសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ តាមវិធាន៦៩(១)។ ដូច្នេះ យើងខ្ញុំសូមលើកឡើងថា នីតិវិធីយន្តការដំណោះស្រាយអនុវត្តតែនៅពេលដែលកំពុងតែរៀបចំចេញដីកាដំណោះស្រាយ មិនមែនពេលចេញហើយ ឬក៏ពេលចេញហើយដូច្នោះទេ។ ខ្ញុំយល់ឃើញថា ខ្ញុំបានឆ្លើយសំណួរលោកចៅក្រមហើយ។

**ចៅក្រម កាង ជីនបាក់៖**

*យេស ៗ*។ បាទ លោកបានឆ្លើយសំណួរខ្ញុំហើយ។

**លោក ម៉ៃខល កាណាវ៉ាស៖**

ប្រហែលជាលោកចៅក្រមមានសំណួរផ្សេងទៀត។

**ចៅក្រម កាង ជីនបាក់៖**

លោកនិយាយអំពីបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អ៊ីចឹងមែនទេ?

**លោក ម៉ៃខល កាណាវ៉ាស៖**

បាទ។

**ចៅក្រម កាង ជីនបាក់៖**

នៅក្នុងកថាខណ្ឌ៣៧ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គាត់បានលើកឡើងថា នៅក្នុងបណ្តឹងឧទ្ធរណ៍លោកលើកឡើងថាវិធាន៧២ ស្តីពីការមិនព្រមព្រៀងគ្នានេះ នីតិវិធីដែលជាដាច់ខាតនេះគឺថា សហបានសម្រេចចេញដីកានេះដោយមិនបញ្ជូន ដោយមិនបានស្នើសុំទៅអង្គជំនុំជម្រះឲ្យដោះស្រាយទេ។ ឥឡូវនេះលោកជ្រើសរើសយកសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ មិនអ៊ីចឹង?

**លោក ម៉ៃខល កាណាវ៉ាស៖**

--*(គ្មានការបកប្រែ)*

**ចៅក្រម កាង ជីនបាក់៖**

ខ្ញុំចង់ឲ្យលោកបញ្ជាក់ចំណុចនេះឯង។

**លោក ម៉ៃខល កាណាវ៉ាស៖**

បញ្ហាលោក អៀង សារី នេះគឺជារឿងយូរមកហើយ ប៉ុន្តែតាមការដែលខ្ញុំយល់ច្បាស់នោះគឺ ខ្ញុំបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើងខ្ញុំហើយ បើសិនណាបណ្តឹងឧទ្ធរណ៍របស់

យើងខ្ញុំ គឺបញ្ចាក់ច្បាស់រួចហើយលោកចៅក្រម។

**ចៅក្រម កាង ជីនបាក់៖**

អ៊ីចឹងនៅពេលចេញដីកាដំណោះស្រាយវិធាន៧៧ អាចយកមកអនុវត្តបាន អ៊ីចឹងមែនទេ?

**លោក ម៉ៃខល កាណាវ៉ាស៖**

**បាទ** អាចយកមកអនុវត្តបាន ប៉ុន្តែយើងខ្ញុំសូមលើកឡើងថា នៅពេលមើលវិធាន៧៧(១៣) បញ្ហាដែលយើងកំពុងតែមាន។

**ចៅក្រម កាង ជីនបាក់៖**

ឥឡូវនេះខ្ញុំសូមឲ្យលោកស្តាប់ ដើម្បីឲ្យលោកត្រៀមឆ្លើយ។ សំណួរទី២របស់ខ្ញុំគឺ លោកហាក់បីដូចជាបង្កប់ន័យថា សហព្រះរាជអាជ្ញា ៧៧(១៣)(ខ) ជាច្បាប់ពិសេស ពីព្រោះវិធាននេះដោះស្រាយជាពិសេសចំពោះ (ដកស្រង់)“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ” គឺមិនពាក់ព័ន្ធដោយសារតែវិធាន៧៧(១៣) អនុវត្តបានតែទៅលើដីកាដំណោះស្រាយរួមប៉ុណ្ណោះ ប៉ុន្តែលោកជំទាស់ថាអ្នកតាក់តែងសេចក្តីព្រៀងវិធានបានប្រមើលដឹងជាមុនថា សហចៅក្រមស៊ើបអង្កេតអាចចេញដីកាដំណោះស្រាយផ្ទុយគ្នា ដែលមានសុពលភាព ដោយសម្រេចអនុវត្តតាមវិធានបញ្ជូនដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ អនុ-លោមតាមវិធាន៧២ នៃវិធានផ្ទៃក្នុង ហើយទុកឲ្យភាគីនានាប្តឹងឧទ្ធរណ៍ទៅនឹងដីកាទាំងនោះ ដោយអនុលោមតាមវិធាន៧៧។

[១២:៤៥:៣០]

**លោក ម៉ៃខល កាណាវ៉ាស៖**

បាទ ខ្ញុំសុំឆ្លើយ សាកល្បងឆ្លើយឲ្យបានច្បាស់លាស់។ យើងអនុវត្តវិធាន៧៧ សម្រាប់ដីកាដំណោះស្រាយនេះគឺ -- ហើយអង្គបុរេជំនុំជម្រះក៏មិនអាចបដិសេធចំណុចនេះបានដែរ។ នៅក្នុងអនុកថាខណ្ឌ ៧៧(១៣) មិនអនុវត្តនៅក្នុងករណីចំពោះមុខនេះទេ ដោយសារតែអត្ថិភាពនៃដីកាដំណោះស្រាយពីរផ្ទុយគ្នានេះ។ អ៊ីចឹងបើយើងមើលវិធាន ៧៧(១៣) អ្នកធ្វើសេចក្តីព្រាងច្បាប់គាត់បាន -- ហើយយើងក៏មិនដែលមានយុត្តិសាស្ត្រណាបែបនេះដែរ។ ដូច្នេះ យើងខ្ញុំយល់ស្របថា គឺជាការប្រមើលដឹងជាមុន ពីសំណាក់អ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុងដែលថា យើងអាចអនុវត្តវិធាណ ៧៧(១៣) នៅក្នុងករណី -- ជាពិសេសវិធាន ៧៧(១៣)(ក) និង(ខ) គឺថានៅពេលដែលយើងមានដីកាដំណោះស្រាយដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នៅក្នុងចំណុច(ក) គឺសំណុំរឿងមាននៅក្នុងឃ្លាំងផ្ទុកឯកសារហើយ

មាននៅក្នុងបណ្ណសារនេះហើយ ហើយនៅក្នុងសំណុំរឿងដដែលនេះ ដែលនៅក្នុងបណ្ណសាររបស់យើងនេះ គឺថា បើវាមានទាំងពីរអ៊ីចឹងមិនអាចផ្សះផ្សាគ្នាបានទេ មិនអាចសម្របសម្រួលគ្នាបានទេ។ បើនិយាយពីច្បាប់ពិសេសវិញ គឺ យើងនិយាយតែក្នុងករណីដែលមានដីកាដំណោះស្រាយតែមួយ គឺអាចជាដីកាលើកលែងការចោទប្រកាន់ ឬក៏តែជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ពេលហ្នឹងយើងមើលទៅចំណុច (ក),(ខ) នៃវិធាន៧៧(១៣) នេះ។ ប៉ុន្តែបើមានដីកាពីរបែបនេះមិនអាចធ្វើដូច្នេះបានទេ។ គឺមិនអាចអនុវត្តបានទេ។ អ៊ីចឹងហើយបានជាលោកចៅក្រមត្រូវតែអនុវត្តគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទនេះ ក្នុងករណីដែលមានដីកាពីរបែបនេះ។ ហើយដីកាដំណោះស្រាយទាំងពីរនេះគឺថា វាមានសុពលភាពស្មើគ្នា មិនមានមួយណាអាចត្រូវចាត់ទុកមួយណាថាមោឃៈបាននោះទេ។ អ៊ីចឹងយើងខ្ញុំយល់ឃើញថា វិធាន៧៧(១៣)(ខ)គឺជាច្បាប់ពិសេសហើយ។

[១២:៤៨:១៨]

**ចៅក្រម កាង ជីនបាក់៖**

អ៊ីចឹងលោកចង់ថា ភាគីនៃកិច្ចព្រមព្រៀងគឺថា ទុកចន្លោះប្រហោងនេះ ឬក៏លោកចង់និយាយថានៅក្នុងវិធាន៧៧(៣) គេមានគំនិតផ្សេង?

**លោក ម៉ៃខល កាណាវ៉ាស៖**

នៅពេលដែលអ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុងគាត់មានការបារម្ភ ទី១ -- គឺយើងត្រូវពិចារណាទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយសំអាងទៅលើធ្វើម៉េចរកឲ្យបានសំឡេងភាគច្រើនលើសលុបដាច់ខាត ឬយ៉ាងណានោះ។ ក៏ប៉ុន្តែឥឡូវនេះយើងមានចៅក្រមពីរឯករាជ្យ មានឋានៈស្មើគ្នា ហើយដោយសារតែគាត់ឯករាជ្យ និងមានឋានៈស្មើគ្នានេះ សំណើដ៏ទទូចរបស់យើងខ្ញុំគឺថា អ្នកចរចាគាត់យល់ថា យើងមិនអាចមានចៅក្រមមួយមានអានុភាពជាងចៅក្រមមួយទៀតទេ។ អ៊ីចឹងគឺទុកឱកាសថានៅពេលដែលចៅក្រមគាត់រកឃើញថា គាត់មានការមិនចុះសម្រុងគ្នា គាត់ត្រូវបង្ហាញជំហររបស់គាត់ប្រកបទៅដោយហេតុផល ដោយមិនរំលោភទៅលើម្ខាងទៀតដែលមានឋានៈស្មើគ្នានោះទេ។ អង្គការសហប្រជាជាតិមិនដែលមានបំណង ហើយខ្ញុំក៏គិតថាអង្គការសហប្រជាជាតិមិនគិតថា វាជួបស្ថានភាពបែបនេះដែរ ក៏ប៉ុន្តែទទួលស្គាល់ថាកាលណាយើងមានចៅក្រមពីរ មានឋានៈស្មើគ្នា ហើយមិនផ្តល់ ទុកឱកាសឲ្យគាត់នោះទេ គឺប្រហែលជាគាត់អាចធ្វើការ គាត់អាចសម្រេចខុសៗគ្នាវាមានលទ្ធភាពអ៊ីចឹង ហើយបើវាអ៊ីចឹងដីកាដំណោះស្រាយមួយ បើមិនមានចន្លោះប្រហោងអ៊ីចឹង គាត់ចេញ

ដំណោះស្រាយតែមួយបាត់ទៅហើយ។ មិនមានអ្វីគួរ -- ដើម្បីកុំឲ្យវាមានវិមតិសង្ស័យទៅលើអង្គហេតុណាមួយក្នុងចំណោមពួកគាត់ទាំងពីរ អ៊ីចឹងវិមតិសង្ស័យហ្នឹង គឺគាត់ប្រាកដជាច្រានរឿងនេះចោលហើយ ហ្នឹងបើគាត់អនុវត្តគោលការណ៍នេះ។ ហ្នឹងខ្ញុំយល់យ៉ាងដូច្នេះឯង។ យើងត្រូវតែមើលឯកសារទាំងអស់ យើងត្រូវមើលគ្រប់ឯកសារទាំងអស់ អង្គការសហប្រជាជាតិមិនបានចែករំលែកឯកសារទាំងអស់នោះមកឲ្យយើងទេ។ អ៊ីចឹងវាពិបាកប្រាប់ដែរ ខាងភាគីរដ្ឋាភិបាលក៏អ៊ីចឹង មិនបានផ្ដល់ឯកសារទាំងអស់នេះមកឲ្យយើងទេ។ អ៊ីចឹងជាកត្តាសមហេតុផលគឺថា ដោយសារចៅក្រមទាំងពីរគាត់មានឋានៈស្មើគ្នា គាត់អាចចេញបែបដូច្នោះបានហើយ។ អ៊ីចឹងយើងមិនអាចចាប់បង្ខំទៅលើឆន្ទៈរបស់ចៅក្រមឯករាជ្យណាមួយទេ។ នេះគឺជាបញ្ហា។

**ចៅក្រម កាង ជីនបាក់៖**

សូមអរគុណច្រើន។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គបុរេ៖**

បាទ សវនាការរបស់យើងបានឈានដល់ទីបញ្ចប់។ យើងបានបំពេញការងារអស់រយៈពេលពីរថ្ងៃកន្លះ។ ហើយមុននឹងបញ្ចប់ ក៏យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកចៅក្រម លោក លោកស្រីជាព្រះរាជអាជ្ញា និងលោកជាសហមេធាវីទាំងអស់ ព្រមទាំងបុគ្គលិកទាំងអស់ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងសវនាការក្នុងរយៈពេលពីរថ្ងៃកន្លះ។ ដូច្នេះ ខ្ញុំសូមប្រកាសបិទសវនាការ៕

*(សវនាការបញ្ចប់នៅម៉ោង ១២:៥២ នាទី)*